# ជម្ពូទីបរណ៍ភកចា

បរមត្ថទីបក

គឺ

បណ្ឌិត ឃឹម · ទូច

រៀបរៀង

ឧបត្ថម្ភអ្នកសិក្សាធម្មវិន័យថ្នាក់ឯក

បោះពុម្ពលើកដម្បូង

គឺ:

ទី

ម្ចាស់



ជីវ-ខ្លួនឯង

ពុម្ពាគារ **ជីវខ្លួនឯង** លេខ ៣០ ស្ទឹង

...ចំណាស់ ខាងកើតផ្សារធំថ្មី ក្រុងភ្នំពេ... វិថីអគ្គិ...

ព· ស· ២៤៩៦ គ· ស· ១...

# ជម្ពូទបរណាកថា

បរមត្ថបដិបទា

គឺ

បណ្ឌិត ឈឹម - នួច

រៀបរៀង

ឧបត្ថម្ភសាលាធម្មវិន័យថ្នាក់ឯក

បោះពុម្ពលើកដំបូង

ចិរំ ធិប្បតុ ជិនសាសនំ!

“ សូមឲ្យសាសនាព្រះជិនស្រី រុងរឿងពិសីជាអន្វេន!

ការផ្សាយរបស់

បណ្ណាគារ ជីន - ជួង - ហួត លេខ ៣០ ស្ទួន

វិថីប៉ាស្ទ័រ ខាងកើតផ្សារធំថ្មី ក្រុងភ្នំពេញ

ព.ស. ២៤៩៦

---

គ.ស. ១៩៥៣

# មាតិកាប័ត្រ

ឈ្មោះធម៌ . . . . . . . . . . . . . . . . . . . លេខទំព័រ

១– និព្វិទា = សេចក្តីនឿយណាយ . . . . . . . . ១

២– វិរាគៈ = ការអស់ទៅនៃរាគៈ . . . . . . . . . . ១៨

៣– វិមុត្តិ = សេចក្តីរួចស្រឡះ . . . . . . . . . . ២០

៤– វិសុទ្ធិ = សេចក្តីស្អាត . . . . . . . . . . . . ២៣

៥– សន្តិ = សេចក្តីស្ងប់ . . . . . . . . . . . . ២៥

៦– និព្វាន = . . . . . . . . . . . . . . . . . ២៦

# មុននឹងមើលអានឬសិក្សាសៀវភៅនេះ ត្រូវកែពាក្យសិន តាមគំរូខាងក្រោមនេះ៖

—·XoX·—

| ទំព័រ | បន្ទាត់ | ពាក្យថា | ត្រូវកែជា |
|---|---|---|---|
| ៥ | ៦ | វិស្សនាញាណ | វិបស្សនាញាណ |
| ៧ | ១១ | អាទីនវានុស្សនាញាណ | អាទីនវានុបស្សនាញាណ |
| " | ១៦ | ទុក្ខិត្តា សិតវេទកា | ទុក្ខិត្តាសិតវេទកា |
| ៨ | ១៧ | តក់សត្លុ | តក់ស្លុត |
| ១១ | ៩ | អាម្មរណ៍ | អារម្មណ៍ |
| ២២ | ១៦ | លោកីយ | លោកិយ |
| ២៧ | ១៤ | គណា | គណ្ហា |
| ៣១ | ៤ | គឿនត្រាំ | គ្រឿនត្រាំ |
| ៥៣ | ៣ | ផ្កាចម្បា | ផ្កាចម្ប៉ា |
| " | ៥ | ទិ ញ | ទី ញ |
| " | ៦ | ផ្កាចម្បា | ផ្កាចម្ប៉ា |
| ៥៨ | ៤ | ត្រេអរ | ត្រេកអរ |
| " | ១៤ | អប្បមាទ | អប្បមាទ |
| ៥៨ | ១៦ | យម្លិ | យម្ហិ |

| | | | |
|---|---|---|---|
| ៦៣ | ៦ | មីនមែន | មិនមែន |
| " | ១៨ | ធធ្វិចរណា | ធម្វិចរណ |

# បណ្តាំ

—·×·—

អស់លោកមើលអានឬសិក្សា　　សូមមានមេត្តាត្រាប្រណី
សន្តោសកុំកាលបន្ទោសស្តី　　ព្រោះមានសេចក្តីខ្វះកម្រ ។
បើឃើញពាក្យណាដែលខុសឆ្គង　　មិនត្រូវចំនងវេយ្យាករណ៍
សូមជួយកែផងឱ្យបានល្អ　　ត្រូវតាមទិករអក្សរសាស្ត្រ ។
ព្រោះការរៀបរៀងមិនទៀងទាត់　　អក្សរពុម្ពភ្លាត់លោកប្រឡះ
ឃ្លាតឃ្លៀងភ្លាត់ផ្ទះទៅផ្តេសផ្តាស　　សូមបារបំប៉ះបំពេញផង ។
ឬមួយក្រែងមានពាក្យជ្រុលជ្រួស　　មតិឆោងហួសពុទ្ធបំណង
ដែលទ្រង់ទោសខាមានពួកគង　　ទុកឱ្យសត្វផងប្រតិបត្តិតាម ។

( ឃុន-ស៊ិមប៊ូរ កវីនិពន្ធបណ្ឌិត )

# អាទិបទ

មូលហេតុដែលនាំឲ្យកើតសៀវភៅ "ធម្មវិវរណកថា" បរមត្ថបដិបទា នេះឡើង ដោយសេចក្ដីយល់ឃើញថាៈ នៅ-ក្នុងកម្ពុជរដ្ឋយើងសព្វថ្ងៃនេះ វាជាការបានផ្ដើមឲ្យមានសាលាធម្មវិន័យក្នុងព្រះរាជាណាចក្រគ្រប់វត្ត, ហើយក្បួនច្បាប់ឧបត្ថម្ភដល់សាលាធម្មវិន័យទាំងនោះពុំមានបរិបូណ៌ ពួកភិក្ខុសាម-ណេរដែលជួបប្រទះនឹងខ្ញុំ តែងត្អូញត្អែរចង់បានឲ្យកើតសៀវ-ភៅនេះឡើង អាស្រ័យហេតុនេះហើយ បានជាខ្ញុំខំយកចិត្តទុកដាក់រៀបរៀងសៀវភៅនេះឲ្យកើតឡើងដរាបដល់ចប់ ដើម្បីឧបត្ថម្ភដល់អ្នករៀនសាលាធម្មវិន័យទាំងនុ៎ះ លុះរៀបរៀងរួចស្រេចហើយខ្ញុំបានពឹងមហាឧត្តមវិជ្ជា "ឃុន-គិមប៊ូរ" ឲ្យជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួលពាក្យ ខុសត្រូវដរាបដល់ចប់ រួចហើយបានប្រគល់សៀវភៅនេះឲ្យទៅថៅកែ "ជឹង-ងួន-ហួត" ជាអ្នកកម្មសិទ្ធិទុកនឹងបោះពុម្ពផ្សាយជាសាធារណប្រយោជន៍ក្នុងព្រះពុទ្ធសាសនាតទៅ ! ។

ដោយអំណាចវិរិយភាពនៃការរៀបរៀងសៀវភៅនេះ សូមឲ្យសាសនានៃព្រះត្រៃលោកាចារ្យក្នុងពិភពលោក រុងរឿងអស់

កាលជាអង្វែងតទៅ ។

ម្យ៉ាងទៀត សូមសិក្ខាកាមសង្ឃបានសះម្រែបតាមគោលបំណង កុំបីក្លាយទៅជាប្រការផ្សេងៗឡើយ ។

ម្យ៉ាងវិញទៀត សូមអភ័យទោសអំពីសំណាក់នៃវិញ្ញូជនទាំងឡាយ បើឃើញខុសឆ្គងសេចក្តីត្រង់ណា សូមកែតម្រង់ឲ្យទានផង, បើគ្រាន់តែសន្ទិះសង្ស័យទេ សូមពិគ្រោះនឹងខ្ញុំជាអ្នករៀបរៀងសិន ក្រែងមានការយល់ខុសគ្នា ។

ភ្នំពេញ, ថ្ងៃ ១ ៗ ១៣ ៦ ឆ្នាំម្សាញ់បញ្ចស័ក

ព.ស. ២៤៩៦ (១០.៥.៥៣)

បណ្ឌិត ឈឹម-ទូប

# ធម្មវិចារណកថា

នមត្ថុ សុគតស្ស

សូមនមស្ការ បំពោះព្រះសុគត (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយគោរព ។

## ១– និព្វិទា=សេចក្ដីនឿយណាយ

ឧទ្ទេសៈ

១_ ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ

ជនទាំងឡាយ ចូរមកមើលនូវលោកនេះ (គឺខន្ធលោក) មានឧបមាដោយរាជរថ ដ៏វិចិត្រហើយ ដែលពួកជនពាលលិចនៅ, កិលេសជាគ្រឿងជាប់ជំពាក់ រមែងមិនមានដល់បណ្ឌិតទាំងឡាយ កាលដឹងច្បាស់ឡើយ ។

២_ យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា

អ្នកណាសង្រួមចិត្ត, អ្នកនោះរួចផុតចាកចំណងរបស់មារ ។

និព្វិទា= សេចក្ដីនឿយណាយក្នុងបញ្ចក្ខន្ធដោយប្រាជ្ញា មិនមែននឿយណាយ តាមអាការៈរបស់ស្ត្រី ឬបុរស ដែលកើតសេចក្ដីនឿយណាយនឹងគ្នាទៅវិញ ទៅមកនោះឡើយ ។

## អធិប្បាយថាៈ

ពាក្យថា "លោក" ប្រែថា "វិនាស, សាបសូន្យ អន្តរាយ" ។

### លោកបែកជា ២ គឺៈ

១– លោកដោយត្រង់ បានដល់ផែនដី ជាទីនៅអាស្រ័យ ។

២– លោកដោយអម បានដល់ពួកសត្វដែលអាស្រ័យនៅលើផែនដី ។

### សភាពរបស់លោក

ក្នុងលោក គឺប្រជុំមនុស្ស ទាំងទីសំណាក់ មានលក្ខណៈជា៣គឺៈ

១– របស់ដែលឲ្យទោស ដោយបំណែកមួយ ប្រៀបដោយថ្នាំពិស ។

២– របស់ដែលឲ្យទោស ក្នុងកាលកើតសេចក្ដីល្អ ប្រៀបដោយរបស់មានស្រវឹង ។

៣– របស់ដែលជាឧបការៈ ប្រៀបដោយអាហារនឹងភេសជ្ជៈជាទីសប្បាយក៏មាន តែប្រើខុសផ្លូវទៅជាទោសក៏មាន ។

ទិព្វិ៣

## ពាលជន

ជនអ្នកមិនបានពិចារណា មិនឃើញទោស រមែងស្រ-វឹងក្នុងរបស់ដែលឲ្យទោស ហើយលះបង់របស់ដែលជាគុណបោល រមែងនៅក្នុងរបស់ដែលជាឧបការៈ ឈ្មោះថាលិចចុះនៅក្នុងលោក ដូច្នេះ, រមែងបានសោយសុខខ្លះ ទុក្ខខ្លះ តែបើសុខ ក៏ត្រឹមតែសាមិសសុខ ជាហេតុជាប់ជំពាក់ ។

## បណ្ឌិតជន

បំណែកបណ្ឌិត ពិចារណាឃើញសេចក្ដីពិត ក្នុងរបស់នោះ មិនជាប់ជំពាក់ចិត្ត ជាឥស្សរៈដោយខ្លួនឯង ដូច្នេះរមែងបានសុខ ជានិរាមិសសុខ ជាសុខដ៏ក្រៃលែងកើតឡើងក្នុងខាងក្នុងខ្លួនស្ងាត់ ។

## ពុទ្ធបំណង

សម្ដេចព្រះបរមសាស្ដា បានត្រាស់ឲ្យពួកយើងមកមើលនូវលោក ដែលប្រៀបដោយរាជរថ ដែលតាក់តែងល្អដ៏វិចិត្រនោះ មិនមែនដើម្បីឲ្យលិចលង់ចុះក្នុងលោកនេះទេ ដើម្បីឲ្យឬងចិត្តចុះទៅដល់គុណទោស ប្រយោជន៍ មិនមែនប្រយោជន៍

នៃរបស់នោះៗ ដែលចូលក្នុងលោកនេះឡើយ ។

## អាការៈសង្រួមចិត្ត

អាការៈសង្រួមចិត្តមាន៣ប្រការគឺៈ

១– សង្រួមឥន្រ្ទីយ៍ទាំង៦ មិនឲ្យមានសេចក្តីត្រេកអរ ក្នុងកាលដែលឃើញនូវអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលជាទីប្រាថ្នា ។

២– មនសិការកម្មដ្ឋាន ដែលជាបដិបក្ខដល់កាមឆន្ទៈ គឺអសុភនឹងកាយគតាសតិ ឬមរណស្សតិ ។

៣– ចំរើនវិបស្សនា គឺពិចារណាសង្ខារញែកចេញ ជាខន្ធសន្និដ្ឋានសភាពមិនទៀង, ជាទុក្ខ, ជាអនត្តា ។

## មារ

កិលេសកាម បានដល់ចេតសិក ដែលជាទីសៅហ្មង ជាទីប្រាថ្នា ជាទីស្រឡាញ់ គឺតណ្ហា, រាគៈ នឹងអរតិជាដើម ចាត់ជាមារ ព្រោះជាទោសបំផ្លាញគុណគឺសេចក្តីល្អ របស់មនុស្សៗ

វត្ថុកាម គឺរូប, សំឡេង, ក្លិន, រសនឹងផោដ្ឋព្វ ដែលជារបស់គាប់ចិត្ត ចាត់ជាបំណងរបស់មារ ។

វិបស្សនា ៩

## ចំរើន វិបស្សនា

បុច្ឆា- ចំរើន វិបស្សនានោះ តើចំរើនដូចម្ដេច?

វិស្សជ្ជនា- ចំរើនវិបស្សនានោះ គឺពិចារណាខន្ធ៥ ដោយវិបស្សនាញាណទាំង៩ ។

បុ. វិបស្សនាញាណ៩ នោះ គឺអ្វីខ្លះ? ចូររាប់និងអធិប្បាយមកមើល។

វិ. វិបស្សនាញាណ ៩ ដូច្នេះគឺៈ

១- ឧទយព្វយានុបស្សនាញាណ= បញ្ញាពិចារណាឃើញនូវសភាពកើតឡើង និងរលត់សូន្យទៅនៃសង្ខារ ដូចជាពពុះទឹកដែលប៉ោងឡើងហើយបែកធ្លាយទៅវិញ ។

២- ភង្គានុបស្សនាញាណ= បញ្ញាពិចារណាឃើញនូវកិរិយាបែកធ្លាយនៃសង្ខារ គឺឃើញថាៈ ឧប្បាទ, ឋិតិ, ភង្គៈ, ឧប្បាទៈជាជាតិទុក្ខ, ឋិតិ ជាជរាទុក្ខ, ភង្គៈជាមរណទុក្ខ; ដូចជាទឹកសន្សើម ដែលជាប់នៅលើចុងស្មៅ, ព្រះអាទិត្យរះឡើងកាលណាក៏ស្ងួត ហែងហួតអស់ទៅមួយរំពេច យ៉ាងណាមិញ,

បំណែកខាង សង្ខារដែលកើតឡើងហើយសូន្យទៅវិញ ក៏យ៉ាងនោះដែរ ។

៣- ភយតុបដ្ឋានញ្ញាណ= បញ្ញាពិចារណាឃើញថាសង្ខារជាធម្មជាតិគួរខ្លាច ដូចគេខ្លាចសត្វសាហាវ មានសត្វសីហៈជាដើម ព្រោះថា សង្ខារណា ដែលកន្លងហួសទៅហើយ, សង្ខារនោះ ក៏រលត់ទៅ; សង្ខារណា ដែលកំពុងមាននៅក្នុងបច្ចុប្បន្ន, សង្ខារនោះ ក៏រលត់ទៅក្នុងបច្ចុប្បន្ន; សង្ខារណាដែលមិនទាន់មានមក ក៏សង្ស័យទុកជាមុនថា មុខជានឹងបែកធ្លាយទៅ ឧបមាដូចជាស្រី មានកូនបីនាក់ មានទោសកំហុសនឹងព្រះរាជអាជ្ញា, ព្រះរាជាមានព្រះរាជបង្គាប់ត្រាស់បង្គាប់ឲ្យពេជ្ឈឃាតនាំយកទៅសម្លាប់ មាតាក៏ដើរតាមកូនដែលពេជ្ឈឃាតនាំទៅនោះ លុះដល់កន្លែងសម្រាប់សម្លាប់ហើយ, ពេជ្ឈឃាត ក៏កាត់ក្បាលកូនច្បងជាដំបូង លុះស្លាប់កូនច្បងនោះហើយ ទើបប្រារព្ធនឹងសម្លាប់កូនកណ្ដាលនោះទៀត, ស្ត្រីនោះ កាលបើឃើញនាយពេជ្ឈឃាត កាត់ក្បាល

កូនច្បងហើយប្រារព្ធនឹងកាត់ក្បាលកូនបន្ទាប់ទៀត, ក៏អស់សេចក្ដីអាឡោះអាល័យនឹងកូនពៅដោយគិតថា មុខជាគេនឹងសម្លាប់កូនពៅទៀតមិនខាន; ព្រះយោគី ពិចារណាឃើញសង្ខារជាអតីតរលត់ទៅនោះ ដូចជាស្ត្រីឃើញពេជ្ឈឃាតកាត់ក្បាលកូនច្បង, ដែលឃើញនូវសង្ខារជាបច្ចុប្បន្នរលត់ទៅនោះ ដូចជាស្ត្រីឃើញពេជ្ឈឃាតកាត់ក្បាលកូនបន្ទាប់, ដែលឃើញនូវសង្ខារជាអនាគត មុខជានឹងបែកធ្លាយទៅ ដូចជាស្ត្រីអស់ការអាឡោះអាល័យនឹងកូនពៅ ។

៤- អាទីនវានុបស្សនាញាណ= បញ្ញាពិចារណាឃើញទោសរបស់សង្ខារ មិនគួរស្ម័គ្រចិត្ត ដូចគេឃើញផ្ទះភ្លើងឆេះ ហើយភៀសខ្លួនចេញពីផ្ទះនោះទៅ; ពុំនោះដូចជាគេឃើញទោសក្នុងភពទាំងបី ដ៏វិចិត្របគាដោយឯងើកភ្លើង ចត្តារោ មហាភូតា ឃោរវិសាសីវិសា វិយ មហាភូតរូប ៤ ដូចជាពស់មានពិសដ៏ពន្លឹក, បញ្ចក្ខន្ធា ឧក្ខិត្តាសិតវធកា វិយ បញ្ចក្ខន្ធ៥ ដូចជាខ្មាំង៥នាក់ លើកដាវឡើងបំរុងនឹងប្រហារ អ្នកដំណើរ

ដែលដើរទៅតាមផ្លូវ, ឆ អជ្ឈត្តិកាយតនានិ សុញ្ញគាមោ វិយ អាយតនៈខាងក្នុង៦ ដូចជាស្រុកដ៏ស្ងាត់ជាទីរហោឋាន, ឆ ពាហិរាយតនានិ គាមឃាតកចោរា វិយ អាយតនៈខាងក្រៅ៦ ដូចជាចោរចាំសម្លាប់អ្នកស្រុក, សត្តវិញ្ញាណដ្ឋិតិយោ នវសត្តាវាសោ ឯកាទសហិ អគ្គីហិ អាទិត្តា សម្បជ្ជលិតា សញ្ជោតិភូតា វិយ ប វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ ដូចជាគប់ភ្លើងទាំង ១១ឆេះសន្ធោសន្ធៅ ទៅលើពពួកសត្វដែលដេកលក់ក្នុងផ្ទះ គឺសង្សារវដ្ត, សព្វេ សង្ខារា វិយ សង្ខារទាំងអស់ដូចជាជំងឺ និងរោគាពាធគ្រប់យ៉ាង កើតឡើងប្រាកដដល់ព្រះយោគី ដែលពិចារណាឃើញទោសរបស់សង្ខារជាក់ច្បាស់ ដូចបុរសមានភ័យប្រាថ្នាចង់បានសេចក្តីសុខ រត់ទៅរកព្រៃផ្រិក បែរទៅឯព្រៃនោះ សុទ្ធតែបន្លាជិតស្និទ្ធបូលមិនរួប បុះទឹកមានអារក្សទឹក ឬក្រពើ ជាដើម ដើរតាមផ្លូវប្រទះនឹងចោរ នៅក្នុងភូមិមានសុទ្ធតែសេនាទាហាន, បុរសនោះឃ្លានបាយណាស់ ដាក់មើលទៅភោជនសុទ្ធតែថ្នាំពិស ហើយក៏ភិតភ័យតក់ស្លុត

យ៉ាងណាមិញ, ព្រះយោគាវចរឃើញទោសរបស់សង្ខារហើយភិតភ័យខ្លាច ក៏យ៉ាងនោះដែរ ។

៥- និព្វិទានុបស្សនាញាណ = បញ្ញាពិចារណាឃើញទោសក្នុងសង្ខារ ធុញទ្រាន់នឿយណាយរសាយចិត្ត, ដូចជាសត្វរាជហង្សមាសនៅលើកំពូលភ្នំចិត្តកូដ មិនត្រេកអរនឹងរណ្ដៅដែលប្រឡាក់ដោយវត្ថុមិនស្អាតឡើយ ត្រេកអរតែនឹងស្រះធំ៧ប្រការ យ៉ាងណាមិញ, ព្រះយោគីមិនពេញចិត្តនឹងសង្ខារដែលប្រកបដោយទោសផ្សេង ៗ ពេញចិត្តតែក្នុងអនុបស្សនា៧ប្រការ ក៏យ៉ាងនោះដែរ ។

ពុំនោះសោត ដូចជាសត្វសីហៈដែលគេដាក់ក្នុងទ្រុងមាសរមែងមិនត្រេកអរឡើយ តែងត្រេកអរតែក្នុងព្រៃហិមពាន្តតែម្យ៉ាង យ៉ាងណាមិញ, ព្រះយោគីមិនត្រេកអរក្នុងសុគតិភពទាំង ៣ តែងត្រេកអរតែក្នុងអនុបស្សនាញាណ៣ ក៏យ៉ាងនោះដែរ។

៦- មុញ្ចិតុកម្យតាញាណ = បញ្ញាពិចារណាឃើញទោសរបស់សង្ខារ ប្រាថ្នានឹងដោះខ្លួនឲ្យរួចពីខន្ធ ៥ប្រៀប

ដូចត្រី ចង់រួចពីសំណាញ់ ឬពីទំគោក ឬក៏ដូចជាមនុស្សទោស ចង់រួចពីគុកច្រវាក់ខ្នោះឃ្នាង, ពុំនោះដូចសត្វទទាលលក ចង់រួចចេញពីទ្រុង, ពុំនោះសោត ដូចជាពស់ចង់រួចពីកណ្ដាប់ដៃនៃបាតស់ ; ការចង់រួចដូចប្រៀបធៀបមកនេះ ហៅថា " មុញ្ចិតុកម្យតាញាណ " ។

៧ – បដិសង្ខារញ្ញាណ = បញ្ញាពិចារណាឃើញទោសរបស់សង្ខារហើយ រកឧបាយនឹងដោះខ្លួនឲ្យរួចពីខន្ធ ៥ ; ដូចបុរសចាប់ពស់ស្មានថាជាត្រី លុះដឹងថាជាពស់ហើយទើបរកឧបាយនឹងវាយពស់នោះឲ្យអន់ហើយលែងទៅ ដូច្នោះ ។

៨ – សង្ខារុបេក្ខាញាណ = បញ្ញាពិចារណាឃើញទោសរបស់សង្ខារហើយ ក៏តាំងចិត្តជាឧបេក្ខា គឺតោះតើយមិនសោមនស្ស នឹងមិនថ្នាំងថ្នាក់ចិត្ត បំពោះសង្ខារធម៌នោះៗទៀយ ដូចបុរសព្រងើយកន្តើយនឹងប្រពន្ធ ដែលលែងលះគ្នាស្រឡះហើយ ដូច្នោះ ។

៩ – សច្ចានុលោមញ្ញាណ = បញ្ញាដែលអនុលោម

តាមវិបស្សនាញាណទាំង ៨ ខាងដើម, សច្ចានុលោមញាណនេះ បានដល់ជវនទាំង ៣ ខាងដើមគឺៈ បរិកម្មជវន លះកិលេសគ្រោតគ្រាត ១, ឧបចារជវន លះកិលេសយ៉ាងកណ្ដាល១, អនុលោមជវន លះកិលេសយ៉ាងល្អិត ១, ។

វិបស្សនាញាណ ៨ ខាងដើម មានព្រះត្រៃលក្ខណ៍ជាអារម្មណ៍, អនុលោមញាណ មានព្រះពោធិបក្ខិយធម៌ជាអារម្មណ៍, ឧបមាដូចស្ដេចប្រកបដោយរាជធម៌ គង់នៅក្នុងសាលាសម្រាប់កាត់ក្ដី ហើយចាំស្ដាប់ពាក្យមហាមាត្យទាំង ៨ នាក់ដែលជាអ្នកវិនិច្ឆ័យ ទ្រង់ពេញព្រះរាជហឫទ័យចំពោះពាក្យមហាមាត្យនោះ ព្រះអង្គក៏ទ្រង់អនុលោមទៅតាមពាក្យមហាមាត្យដែលវិនិច្ឆ័យត្រឹមត្រូវនោះ យ៉ាងណាមិញ, អនុ-លោមញាណ ដូចជាស្ដេច វិបស្សនា ៨ ទុកដូចជាមហាមាត្យ ពោធិបក្ខិយធម៌ ៣៧ ទុកដូចជាស្ដេចប្រកបដោយរាជធម៌ដែលមានមកពីដើម ក៏យ៉ាងនោះដែរ ។

វិបស្សនាញាណ ៩ នេះ ដូចជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងមើលនូវសង្ខារធម៌ ។

បុគ្គលដែលផុតបំណាងនៃមារនោះ លុះតែបានសង្រួមឥន្ទ្រីយទាំង ៦ ដូចបំរើននូវអសុភកម្មដ្ឋាននឹងកាយគតាសតិកម្មដ្ឋាន ដើម្បីនឹងផ្ចាញ់ផ្ដាល់ចិត្ត ដែលជាប់ជំពាក់ក្នុងកាម ហើយបំរើននូវវិបស្សនាញាណទាំង៩នេះទៅ ទើបរួចពីបំណាងនៃមារបាន ។

បុ. មារ ទាំងអស់មាន ៥ តើមារក្នុងទីនេះ បានដល់មារ ពួកណា? ។

វិ. មារ ក្នុងទីនេះ បានដល់កិលេសមារ ។

បុ. ចុះបំណាងរបស់មារនោះ តើអ្វីខ្លះ? ។

វិ. បំណាងរបស់មារនោះបានដល់វត្ថុកាម គឺរូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វ, បំណាងទាំង៥នេះ ពុំមែនជាបំណាងខ្សែដូចជាខ្សែធម្មតាទេ, ប៉ុន្តែសត្វកម្រនឹងរើបម្រាសកាត់ផ្ដាច់ឲ្យរួច ពីកណ្ដាប់ដៃនៃបំណាងរបស់មារទាំងនេះបានឡើយ ។

## បដិបទារបស់និព្វិទា

### ឧទ្ទេស

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ

និព្វិទា

សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
ឯថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ព្រះយោគាវចរឃើញសង្ខារទាំងឡាយទាំងពួងមិនទៀង, សង្ខារទាំងឡាយទាំងពួង ជាទុក្ខ, ធម៌ទាំងឡាយទាំងពួង ជាអនត្តា ដោយបញ្ញាជាក់ច្បាស់ រមែងនឿយណាយក្នុងសេចក្ដីទុក្ខ ; នេះជាផ្លូវដើម្បីទៅកាន់ព្រះនិព្វាន ។

អធិប្បាយថា

សង្ខារនោះ បានដល់បញ្ចក្ខន្ធ គឺរូប, វេទនា, សញ្ញា, សង្ខារ និងវិញ្ញាណ, សង្ខារនេះ មានប្រភេទផ្សេង ៗ គ្នា តែគង់មានលក្ខណស្មើ ៗ គ្នា គឺជា អនិច្ចតា, ទុក្ខតា, អនត្តតា ។

អនិច្ចតា ភាពនៃសង្ខារជារបស់មិនទៀង រមែងកំណត់ដឹងបានដោយអាការៈអម្បាលនេះគឺ :

១– ក្នុងផ្ទៃដែលងាយ ដោយសេចក្តីកើតឡើងក្នុងខាងដើមនឹងសេចក្តីរលត់ទៅក្នុងខាងចុង ។

២– ក្នុងផ្ទៃដែលល្អិតជាងនេះ រមែងកំណត់ដឹងបានដោយសេចក្តីប្រែប្រួល ក្នុងរវាងការកើតនឹងការរលត់ ។

អាការៈរបស់សង្ខារ

ក) ក្នុងខាងដើមសំដៅយកត្រង់សេចក្តីចំរើន,

ខ) សង្ខារចំរើននឹងវិនាស,

គ) សង្ខារចុះទៅប្រាកដ;

៣– ក្នុងផ្ទៃសុខុម រមែងកំណត់ឃើញសេចក្តីប្រែប្រួលនៃសង្ខារ ។

ក្នុងខណៈមួយគឺមិនតាំងនៅយូរត្រឹមរយៈកាលប៉ុណ្ណោះ ។

សរុបអនិច្ចលក្ខណៈ

១– កិរិយាកើតឡើងហើយរលត់ នឹងសេចក្តីប្រែប្រួលក្នុងរវាងនៃសង្ខារ ដូចបានពោលមកហើយ សរុបចូលក្នុងបាលីថា:

ឧប្បជ្ជតិ ចេវ វេតិ ច អញ្ញថា ច ភវតិ រមែងកើត

ឡើងផង រមែងជារបស់ដទៃផង ជាអនិច្ចលក្ខណៈ ។

២ – អនិច្ចលក្ខណៈនេះ បានដល់សង្ខារពីរគឺ ៖ ឧប្បា-ទិនកសង្ខារ ដែលមានចិត្តគ្រប់គ្រង និង អនុប្បាទិនកសង្ខារ ដែលមិនមានចិត្តគ្រប់គ្រង ។

## ទុក្ខតា ភាពជាទុក្ខ

ភាពជាទុក្ខរបស់សង្ខារ កំណត់ដោយទុក្ខ៥បតទៅនេះ ៖

១ – សភាវទុក្ខ ទុក្ខប្រចាំសង្ខារ គឺជាតិ, ជរា, មរណៈ ។

២ – បកិណ្ណកទុក្ខ ទុក្ខគឺសោកៈ, បរិទេវៈ, ទុក្ខទោម-នស្សៈ ឧបាយាសៈ ។

៣ – និពន្ធទុក្ខ គឺទុក្ខជាប់ជានិច្ច ទុក្ខជាម្ចាស់ផ្ទះ ។

៤ – ព្យាធិទុក្ខ ទុក្ខវេទនា មានប្រភេទផ្សេងៗ តាមសមុដ្ឋាន គឺអវយវៈ ប្រែប្រួលទៅជាធម្មតា ។

៥ – សន្តាបទុក្ខ ទុក្ខគឺសេចក្ដីក្ដៅក្រហាយអន្ទះអន្ទែង បានដល់សេចក្ដីក្រវល់ក្រវាយចិត្ត ព្រោះត្រូវភ្លើងឆេះគឺកិលេស រាគៈ ទោសៈ និងមោហៈ ដុត ។

៦ – វិបាកទុក្ខ ផលរបស់កម្ម បានដល់វិប្បដិសារៈ គឺសេចក្ដីក្ដៅចិត្តជាដើម ។

៧ – សហគតទុក្ខ ទុក្ខប្រព្រឹត្តទៅជាមួយ បានដល់ទុក្ខដែលបាកវិបុលផល ដូចសំដែងក្នុងលោកធម្មសូត្រថា: លាភ, យស, សរសើរ, សុខ ដែលបុគ្គលប្រាថ្នាមិនបានដូចចិត្តក៏ជាទុក្ខ ។

៨ – អាហារបរិយេដ្ឋិទុក្ខ ទុក្ខក្នុងការស្វែងរកអាហារ បានដល់អាជីវទុក្ខ ។

៩ – វិវាទមូលកទុក្ខ គឺទុក្ខមានវិវាទជាមូល បានដល់ការទាស់ទែង នឹងសេចក្ដីមិនព្រមព្រៀងគ្នា ។

១០– ទុក្ខក្ខន្ធ ទុក្ខប្រជុំបញ្ចក្ខន្ធ ដូចពាក្យថា ឧបាទាន-ក្ខន្ធទាំង៥ជាមេទុក្ខ សេចក្ដីកើតឡើងនៃកងទុក្ខទាំងអស់នេះកើតមកអំពីឧបាទានក្ខន្ធទាំង៥ ។

ទុក្ខទាំងអស់នេះ លោកចាត់ជាសភាពត្រូវកើត នឹងវិនាសជាលក្ខណៈ ។

## សរុបទុក្ខលក្ខណៈ

ទុក្ខលក្ខណៈនេះ បានបំពោះក្នុងឧប្បាទិនកសង្ខារ ព្រោះជាចេតសិកធម៌ មិនទូទៅដល់អនុប្បាទិនកសង្ខារផងឡើយ ។

## អនត្តា ភាពមិនមែនជារបស់ខ្លួន

ភាពជាអនត្តានៃសង្ខារ គប្បីកំណត់ដឹងដោយអាការៈអម្បាលនេះគឺៈ

១ – មិននៅក្នុងអំណាច ឬដោយសេចក្តីប្រាថ្នា;

២ – ដោយអត្តា;

៣– ដោយសភាពរកម្ចាស់មិនមាន;

៤ – ជាសភាពសូន្យ;

៥ – ជាសភាវធម៌ប្រព្រឹត្តទៅតាមហេតុប្បច្ច័យជាលក្ខណៈរួមនៃអាការៈទាំងបួន ដែលសំដែងក្នុងបាលីពុទ្ធុទានសេចក្តីថាៈ ក្នុងកាលណាធម៌ទាំងឡាយរមែងប្រាកដដល់ព្រាហ្មណ៍អ្នកពិចារណា ក្នុងកាលនោះ, សេចក្តីសង្ស័យទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ព្រោះដឹងធម៌ដែលប្រព្រឹត្តទៅជាមួយ

នឹងហេតុ នឹងដឹងនូវការអស់ទៅនៃបច្ច័យ ។

## ២_ វិរាគៈ ការអស់ទៅនៃរាគៈ

### ឧទ្ទេសៈ

១_ និព្វិន្ទំ វិរជ្ជតិ នឿយណាយអស់កំណត់ ;

២_ វិរាគោ សេដ្ឋោ ធម្មានំ ការអស់ទៅនៃរាគៈ ឈ្មោះថាប្រសើរជាងធម៌ទាំងឡាយ ;

៣_ សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ វិរាគៈ ប្រព្រឹត្តកន្លងព្រមនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក ។

### សេចក្ដីអធិប្បាយ

បាលីក្នុងអគ្គប្បសាទសូត្រ លោកសំដែងថា វិរាគៈ ជាធម៌ប្រសើរជាងធម៌ទាំងឡាយដែលជាសង្ខតៈ គឺធម្មតាតាក់តែង វិរាគធម៌នេះ ជាអសង្ខតធម៌ គឺធម្មតាមិនបានប្រជុំតាក់តែង បែកជាពាក្យសម្រាប់ហៅជំនួសវិរាគធម៌ដូច្នេះគឺៈ

១- មទនិម្មទនោ ធម៌ញុំាងសេចក្ដីស្រវឹងឲ្យស្វាង ;

វិភគ: ការអស់ទៅនៃភគ:

២- បិបាសវិនយោ ការនាំបង់នូវសេចក្ដីស្រេកឃ្លាន;

៣- អាលយសមុគ្ឃាតោ ការដកឡើងនូវសេចក្ដីអាល័យ;

៤- វដ្ដុបច្ឆេទោ សេចក្ដីកាត់បង់នូវវដ្ដៈ;

៥- តណ្ហក្ខយោ សេចក្ដីអស់ទៅនៃតណ្ហា;

៦- វិរាគោ ការអស់ទៅនៃរាគៈ;

៧- និរោធោ សេចក្ដីរលត់;

៨- និព្វានំ ធម្មជាតអស់ទៅនៃតណ្ហា ។

## អរិយមគ្គអរិយផល

វិរាគៈ ពោលក្នុងលំដាប់និព្វាន បានដល់អរិយមគ្គ; បំណែកក្នុងអគ្គប្បសាទសូត្រ លោកសំដែងថា វិរាគៈ រកធម៌ដទៃស្មើគ្មាន បានដល់អរិយផល ។

## វិធីប្រតិបត្តិ

អ្នកប្រតិបត្តិហាត់ចិត្តទៅតាមធម៌ ដែលពោលទុកនោះគឺប្រតិបត្តិដោយបរមត្ថបដិបទា ។

## សេចក្តីសង្កេត

មានលក្ខណៈសង្កេតម្យ៉ាងថាៈ បរមត្ថបដិបទា លោកសំដែងចំពោះក្នុងផ្លូវលះកិលេសកាម មិនពោលដល់កិលេសចំណែកបដិឃៈឡើយ, តែឃើញថាកិលេសកាម ជាមូលហេតុនៃកិលេសជាបដិឃៈ ។

## ៣- វិមុត្តិ សេចក្តីរួចស្រឡះ

### ឧទ្ទេសៈ

១- វិរាគា វិមុច្ចតិ រមែងរួចស្រឡះ ព្រោះអស់រាគៈ ;

២- កាមាសវាបិ ចិត្តំ វិមុច្ចតិ, ភវាសវាបិ ចិត្តំ វិមុច្ចតិ, អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ ចិត្តរួចផុតហើយចាកអាសវៈ ដែលជាប់ដោយកាម, ចិត្តរួចផុតហើយចាកអាសវៈដែលជាប់ដោយភព, ចិត្តរួចស្រឡះហើយចាកអាសវៈ ដែលជាប់ដោយអវិជ្ជា ;

៣- វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ កាលបើផុតស្រឡះហើយ ញាណ ក៏កើតឡើង ។

### អធិប្បាយថាៈ

កាលបើអស់រាគៈហើយ, ចិត្តរមែងផុតចាកអាសវៈបី, អាសវៈ គប្បីប្រៀបធៀបដោយន័យដូចតទៅនេះ ៖

កាមាសវៈ ធៀបដោយកាមតណ្ហាៈ

ភវាសវៈ ធៀបដោយភវតណ្ហា;

អវិជ្ជាសវៈ ធៀបដោយអវិជ្ជា ។

## សេចក្តីសំគាល់របស់វិមុត្តិ

១_ វិមុត្តិក្នុងលំដាប់នៃវិរាគៈ ដូចមានក្នុងបាលីខាងដើមបានដល់អរិយផល ។

២_ បំណែកវិមុត្តិក្នុងបាលីទី២ លោកសំដែងជាលំដាប់ក្នុងការដឹងនូវអរិយសច្ចទាំង៤ ។

៣_ បាលីទី៣នោះ លោកសំដែងថាញាណមាន១០ ចាកវិមុត្តិ ក្នុងទីដទៃហៅថា វិមុត្តិញាណទស្សនៈ ។

៤_ វិមុត្តិ ក្នុងបាលី មិនបាននិយមក្នុងខណៈនៃមគ្គឬផល លោកចែកជាពីរបំណែកគឺ វិមុត្តិ១ វិមុត្តិញាណទស្សនៈ១ ក្នុងបាលីសំដែងសេខធម្មក្ខន្ធ៥ គឺ សីល, សមាធិ, បញ្ញា

ទាំងបីនេះ ចាត់ជាធម្មក្ខន្ធបំណែកសាមញ្ញ, វិមុត្តិ នឹង វិមុត្តិញ្ញាណទស្សនៈ ចាត់ជាធម្មក្ខន្ធបំណែកវិសាមញ្ញ ។

វិមុត្តិ ដែលជាកិច្ចនៃចិត្តនឹងបញ្ញា

១- វិមុត្តិ គឺវិមុត្តិទី១ ជាកិច្ចនៃចិត្តខាងដើម ;

២- វិមុត្តិ ក្នុងបាលីទី៣ ជាកិច្ចនៃបញ្ញាខាងចុង ។

វិមុត្តិ ដែលជាអរិយមគ្គអរិយផល

១- វិមុត្តិ បានដល់អរិយមគ្គ, វិមុត្តិញ្ញាណទស្សនៈ ជាអរិយផល ;

២- បើបំពោះវិមុត្តិតែមួយ បានទាំងអរិយមគ្គ អរិយផល ។

វិមុត្តិ ដែលជាលោកិយនឹងលោកុត្តរៈ

វិមុត្តិនេះ ចូលចិត្តថា លោកុត្តរៈ តែក្នុងបាលីលោកសំដែងជាពីរផ្នែកគឺ តទង្គវិមុត្តិនឹងវិក្ខម្ភនវិមុត្តិ ទាំងពីរនេះជាលោកិយ ។ សមុច្ឆេទវិមុត្តិ បដិប្បស្សទ្ធិវិមុត្តិ នឹងនិស្សរណវិមុត្តិ ទាំងបីនេះ ជាលោកុត្តរៈ ។

## ៤_ វិសុទ្ធិ សេចក្ដីស្អាត

ឧទ្ទេសៈ

១_ បញ្ញាយ បរិសុជ្ឈតិ រមែងបរិសុទ្ធដោយបញ្ញា ។

២_ ឯស មគ្គោ វិសុទ្ធិយា នេះជាផ្លូវដើម្បីទៅកាន់ព្រះនិព្វាន ។

អធិប្បាយថាៈ

វិសុទ្ធិ ក្នុងបីសាសនា គឺសាសនាព្រាហ្មណ៍ប្រកាន់ថាជម្រះបាប បានដល់ការងូតទឹក, សាសនាគ្រិស្ដ ប្រកាន់ថាបរិសុទ្ធដោយមានព្រះជាម្ចាស់សួគ៌ ជាអ្នកទទួលទោស, បំណែកព្រះពុទ្ធសាសនា បុណ្យបាបកើតមានព្រោះខ្លួនឯងធ្វើ មិនមែនអ្នកណាធ្វើឲ្យឡើយ, បរិសុទ្ធនឹងមិនបរិសុទ្ធ នៅលើខ្លួនអ្នកធ្វើ, ក្នុងន័យនេះ បរិសុទ្ធខាងក្នុង បានដល់បញ្ញា ។

បដិបទានៃវិសុទ្ធិ

លោកសំដែងបដិបទានៃវិសុទ្ធិ ដែលភាពជាបុថុជ្ជនទុំងភាពជាអរិយៈ បានដល់វិបស្សនាញាណ៩ ដូចបានសំដែង

មកខាងដើម ។

### វិសុទ្ធិដទៃទៀត

### ឧទ្ទេសៈ

៣- មគ្គានដ្ឋង្គិកោ សេដ្ឋោ ទស្សនស្ស វិសុទ្ធិយា
ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា

ផ្លូវប្រកបដោយអង្គ ៨ ជាផ្លូវប្រសើរបំផុតជាងផ្លូវទាំងឡាយ , ផ្លូវនោះឯង មិនមានផ្លូវដទៃបរិសុទ្ធជាងទស្សនៈនោះឡើយ ។

### អធិប្បាយបាឋៈ

### ធៀបមគ្គនឹងវិសុទ្ធិ

ផ្លូវនេះ នាំទៅដល់ការម៉តបត់នៃទស្សនៈ ត្រូវដឹងធៀបនឹងវិសុទ្ធិទាំង៧ ដូចតទៅនេះ ៖

សម្មាវាចា, សម្មាកម្មន្តៈ, សម្មាជីវៈ ទាំង៣នេះសង្គ្រោះចូលក្នុងសីលវិសុទ្ធិទី១; សម្មាវាយាមៈ សម្មាសតិ, សម្មាសមាធិ ទាំង៣នេះ សង្គ្រោះចូលក្នុងចិត្តវិសុទ្ធិទី២បានដល់សមាបត្តិ; សម្មាទិដ្ឋិ, សម្មាសង្កប្បៈ ទាំង២នេះសង្គ្រោះចូលក្នុងវិសុទ្ធិទាំង៥; សម្មាសង្កប្បៈ ធ្វើកិច្ចពិចារណា សម្មាទិដ្ឋិ

ផ្ញើកិច្ចសន្និដ្ឋាន ។

### វិសុទ្ធិ ជាលោកុត្តរៈ

បដិបទាញាណទស្សនវិសុទ្ធិ ១, ញាណទស្សនវិសុទ្ធិ ១ ទាំងពីរនេះបាត់ជាលោកុត្តរៈ ក្រៅពីនោះទាំង ៥ បាត់ជាលោកិយៈ ។

## ៥-សន្តិ សេចក្តីស្ងប់

### ឧទ្ទេសៈ

១– សន្តិមគ្គមេវ ព្រូហយ ឡើងកាន់ផ្លូវដ៏ស្ងប់ស្ងាត់;

២– នត្ថិ សន្តិ បរំ សុខំ សុខដទៃក្រៅពីសេចក្តីស្ងប់មិនមាន;

៣– លោកាមិសំ បជហេ សន្តិបេក្ខោ អ្នកសំឡឹងនូវសេចក្តីស្ងប់ គប្បីលះបង់នូវអាមិសក្នុងលោក ។

### អធិប្បាយថាៈ

សន្តិនោះ ប្រព្រឹត្តទៅក្នុងត្រៃទ្វារ, ស្ងប់កាយវាចា ឈ្មោះថា ស្ងប់ខាងក្រៅ, ស្ងប់ចិត្ត ឈ្មោះថា ស្ងប់ខាងក្នុង ។

បញ្ចកាមគុណ ឈ្មោះថាលោកាមិស គឺជាអាមិសក្នុង

លោក ។

សន្តិ ជាលោកិយៈនិងលោកុត្តរៈ

១_ សន្តិ ជាលោកិយៈ បានដល់សេចក្តីស្ងប់ចិត្តមួយពេល ៗ

២_ សន្តិ ជាលោកុត្តរៈ បានដល់លះអាមិសក្នុងលោក ។

៦-និព្វានៈ

ឧទ្ទេសៈ

១_ និព្វានំ បរមំ វទន្តិ ពុទ្ធា=ព្រះពុទ្ធទាំងឡាយ រមែងពោលថា ព្រះនិព្វានជាធម៌ដ៏ក្រៃលែង ។

២_ និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ = បុគ្គលគប្បីជម្រះនូវផ្លូវទៅកាន់ព្រះនិព្វានដោយឆាប់រហ័ស ។

៣_ និព្វានំ បរមំ សុខំ = ព្រះនិព្វានជាសុខដ៏ក្រៃលែង ។

អធិប្បាយថាៈ

បុ. និព្វាន ប្រែថា ដូចម្តេច ?

និព្វាន

វ. និព្វាន ប្រែថា "ចេញផុតអំពីកិលេសជាគ្រឿងរឹតរុំសត្វ ឬថា ជាធម្មជាត ជាទីរំលត់ភ្លើងកិលេសនឹងភ្លើងទុក្ខ" ។

ភ្លើងកិលេសនោះ បានដល់រាគៈ ទោសៈ មោហៈ ព្រោះកើតឡើងមួយអន្លើដោយចិត្ត ធ្វើចិត្តឲ្យល្អក់កករ ឲ្យក្តៅក្រហាយអន្ទះអន្ទែង ។

ភ្លើងទុក្ខ បានដល់ ជាតិ, ជរា, ព្យាធិ, មរណៈ, សោកៈ, បរិទេវៈ, ទុក្ខៈ, ទោមនស្សៈ, ឧបាយាសៈ ព្រោះជាហេតុនៃសេចក្តីទុក្ខនឹងតួទុក្ខ តែងបំពក់សត្វឲ្យក្តៅក្រហាយដូចជាគំនរភ្លើង, មានតែព្រះនិព្វានម្យ៉ាង ដែលជាគ្រឿងរំលត់ភ្លើងទាំងនេះបាន ព្រោះភ្លើងទាំងនេះមិនមាននៅក្នុងព្រះនិព្វាន។ ព្រះនិព្វានជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង មិនមានឧបក្កិលេសជាទីក្ស័យទៅនៃតណ្ហា ។ ព្រះនិព្វាន មិនមែនជាដី មិនមែនជាភ្លើង មិនមែនជាខ្យល់ មិនមែនជាអាកាសានញ្ចាយតនៈ មិនមែនជាវិញ្ញាណញ្ចាយតនៈ មិនមែនជាអាកិញ្ចញ្ញាយតនៈ មិនមែនជានេវសញ្ញានាសញ្ញាយតនៈ មិនមែនជាលោកនេះ មិនមែនជា

លោកខាងមុខ មិនមែនជាព្រះអាទិត្យព្រះចន្ទ្រ ។ ព្រះនិព្វាន មិនមែនជាដំណើរមកពីភូមិនេះ ដល់ភូមិនោះ មិនមែនជាដំណើរទៅពីភូមិនេះ ដល់ភូមិដទៃ មិនមានកិរិយាឈប់នៅ មិនមានចុតិ មិនមានបដិសន្ធិ មិនមានប្រតិស្ឋានតាំងនៅក្នុងទីដំបន់ណាឡើយ ។

ឫ. សភាវៈទាំងពួងដែលបានពោលមកហើយទាំងប៉ុន្មាននេះ ជាសុទ្ធតែមិនមែនព្រះនិព្វានទាំងអស់, បើដូច្នេះមានតែព្រះនិព្វានសូន្យទទេ ទេដឹង?

វិ. មិនមែនដូច្នោះទេ ព្រះនិព្វានមានពិត តែជាធម្មជាតល្អិត សុខុមណាស់; ព្រះអរិយៈទាំងឡាយ តែងឃើញច្បាស់ដោយបញ្ញាចក្ខុ គឺអរិយមគ្គញាណ ព្រោះហេតុនោះ បានជាព្រះនិព្វានជាអសាធារណៈមិនទូទៅ គឺមិនប្រាកដដល់បុថុជ្ជនផង ។

ឫ. បើព្រះនិព្វានមានមែន តើស្ថិតនៅក្នុងទីណា? ជិតឬឆ្ងាយ?

និព្វាន

វិ. ព្រះនិព្វាន ជាអរូបធម៌ មិនមែនមានទីកន្លែងសម្រាប់ស្ថិតនៅ ដូចជារបស់ទាំងពួងដែលមានរូបទេ; ព្រះនិព្វានថាស្ថិតនៅជិតក៏ថាបាន, ថាស្ថិតនៅឆ្ងាយក៏ថាបាន; ដែលថាជិតសំដៅត្រង់អស់ រាគៈ ទោសៈ មោហៈ ត្រង់ណា, ព្រះនិព្វាននៅត្រង់នោះ, ដែលថាឆ្ងាយ គឺព្រះនិព្វានប្រតិស្ឋាននៅត្រង់ទីបំផុតលោកទាំងបីគឺ កាមលោក, រូបលោក, អរូបលោក។

បុ. ព្រះនិព្វានជាធម្មជាតឥតរូបទេ បុះដែលស្ថិតនៅនោះតើមានអ្វីទ្រទ្រង់?

វិ. មានធម្មាយតនៈជាគ្រឿងទ្រទ្រង់ ព្រោះព្រះនិព្វាននឹងធម្មាយតនៈនេះ ជាអរូបធម៌ដូចគ្នា បានជាអាចទ្រទ្រង់គ្នាបាន, ឧបមាដូចជាផ្សែង ដែលជារបស់មានរូបល្អិតពាល់ផ្ទុំមិនបាន តែគង់អាចស្ថិតនៅឰដ៏អាកាស ដូចគ្នាបាន យ៉ាងណា, ព្រះនិព្វានក៏ស្ថិតនៅ យ៉ាងនោះដែរ ។

ព្រះនិព្វាននេះ ប្រាកដជាមានមែន ដូចជាប្រទេសដែលមានផ្លូវដើរ នៅទីបំផុតរបស់ផ្លូវនោះ តែងមានស្រុក, ភូមិ

យ៉ាងណា, ព្រះនិព្វាន ក៏មានអដ្ឋង្គិកមគ្គជាផ្លូវ ឯទីបំផុតផ្លូវ គឺព្រះនិព្វាន ក៏យ៉ាងនោះដែរ ។

ប. ព្រះនិព្វាន មាននៅសល់ធម្មជាតអ្វីដែរឬ?

វិ. មាននៅសល់ផលញាណ តែម្យ៉ាង ។

ប. ផលញាណនោះតើបានមកពីណា?

វិ. បានមកពីការពិចារណានូវខន្ធ ដោយវិបស្សនាញាណទាំង ១០, ឧបមាដូចជាតិដូងទុំ បើទុកយូរទៅវាស្អុយ, បើយកទៅដាំវាដុះទៀត, បើគេមិនបង់ឲ្យស្អុយ មិនបង់ឲ្យដុះទៀត, គេយកទៅចំរាញ់ធ្វើជាប្រេង ដាំក៏មិនដុះ ទុកក៏មិនស្អុយយ៉ាងណា, ព្រះនិព្វាន ដែលចំរាញ់មកពីវិបស្សនាញាណ ក៏មិនមែនសូន្យទទេ ហើយមិនមានពូជតទៅទៀត យ៉ាងនោះដែរ។

ព្រះនិព្វានមានឈ្មោះច្រើនយ៉ាង ដូចតទៅនេះ៖

វិរាគោ= ព្រះនិព្វាន ប្រាសចាករាគៈ គឺដំរេកក្នុងកាមផ្សេងៗ១, និរោធោ = ព្រះនិព្វាន រំលត់បង់នូវភ្លើងទុក្ខ១, ចាគោ = ព្រះនិព្វាន លះបង់នូវតណ្ហា១, បដិនិស្សគ្គោ = ព្រះនិព្វាន

លះបង់បំពោះនូវតណ្ហា ១, មុត្តិ= ព្រះនិព្វាន រួចស្រឡះចាកអាសវៈដែលជាគ្រឿងត្រាំ ១, អនាលយោ= ព្រះនិព្វាន មិនមានអាឡោះអាល័យក្នុងកាមគុណប្រាំ១, រាគក្ខយោ= ព្រះនិព្វាន ជាទីអស់ទៅនៃរាគៈ ១, ទោសក្ខយោ= ព្រះនិព្វាន ជាទីអស់ទៅនៃទោសៈ ១, មោហក្ខយោ= ព្រះនិព្វាន ជាទីអស់ទៅនៃមោហៈ១, តណ្ហក្ខយោ= ព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហា ១, អនុប្បាទោ= ព្រះនិព្វាន មិនបានកើតទៀត១, អប្បវត្តំ= ព្រះនិព្វាន មិនបានប្រព្រឹត្តទៅ១, អនិមិត្តំ= ព្រះនិព្វាន មិនមាននិមិត្ត១, អប្បណិហិតំ= ព្រះនិព្វាន មិនមានអ្វីសម្រាប់ដម្កល់ទុកនូវបញ្ចក្ខន្ធ ១, អនាយូហនំ= ព្រះនិព្វាន មិនបានប្រមូលមកនូវបញ្ចក្ខន្ធ ១, អប្បដិសន្ធិ= ព្រះនិព្វាន មិនមានបដិសន្ធិ១, អប្បដិវត្តតិ= ព្រះនិព្វាន មិនត្រឡប់មកវិញ ១ អគតិ= ព្រះនិព្វាន មិនមានដំណើរទៅពីភពនេះទៅភពនោះ១; អជាតិ= ព្រះនិព្វាន មិនមានជាតិ១, អជរំ= ព្រះនិព្វាន មិនមានជរា១, អព្យាធិ= ព្រះនិព្វាន មិនមានព្យាធិ១, អមតំ=

ព្រះនិព្វាន មិនបេះស្លាប់១, អសោកំ= ព្រះនិព្វាន មិនបេះសោក១, អព្យាបជ្ឈំ= ព្រះនិព្វាន មិនមានសេចក្ដីខ្វល់ខ្វាយ១, អនុបាយាសំ- ព្រះនិព្វាន មិនមានការអាក់អន់ក្នុងចិត្ត១, អសំកិលិដ្ឋំ- ព្រះនិព្វាន មិនមានសេចក្ដីសៅហ្មង១, ។

ពាក្យទាំងនេះ ជាឈ្មោះរបស់ព្រះនិព្វាន ឬជាគុណរបស់ព្រះនិព្វាន ។

បុ. ចុះព្រះនិព្វាន មានលក្ខណៈដូចម្ដេច?

វិ. តយិទំ សន្តិលក្ខណំ ព្រះនិព្វានមានលក្ខណៈរម្ងាប់បង់នូវរាគៈ ទោសៈ មោហៈ រម្ងាប់នូវអវិជ្ជានិងតណ្ហា រម្ងាប់នូវសង្កិលេសធម៌ទាំងពួង ដែលធ្វើឲ្យសៅហ្មង រវិលស្លាប់រវិលកើតក្នុងវដ្ដសង្សារ ។

បុ. ព្រះនិព្វាន មានកិច្ចដូចម្ដេច?

វិ. អច្ចុតិរសំ មានកិច្ចមិនច្យុតិ មិនលុះក្នុងអំណាចនៃសង្ខតធម៌ទាំងឡាយ គឺនាមនិងរូបដែលជាកុសលនិងអកុសលប្រជុំតាក់តែងឲ្យកើតឲ្យបែកធ្លាយ, ព្រោះផុតពីកណ្ដាប់

ដ៏នៃសង្ខតធម៌ ។ ហេតុនេះកិរិយាមិនច្បុតិនេះ ជាកិច្ចរបស់ព្រះនិព្វាន ។ អសង្ខតករសំរ៉ា ម្យ៉ាងទៀត ព្រះនិព្វានមានកិច្ចធ្វើឲ្យសន្តានៃព្រះអរិយបុគ្គលរីករាយសោមនស្ស ។

អធិប្បាយតាមពាក្យព្រះដីកាចារ្យថាៈ

ព្រះនិព្វាននេះ មានអាការហាក់ដូចជាប្រលោមយកចិត្តព្រះអរិយៈ ដែលមានសន្តានធ្លើយណាយចាកសង្សារទុក្ខ ឲ្យប្រកបដោយសេចក្តីក្សេមក្សាន្ត ឲ្យប្រាសចាកទុក្ខ ចាកការក្តៅក្រហាយ ឲ្យមានការត្រជាក់ត្រជំនៅក្នុងខន្ធសន្តាន ។

ប្ុ. ព្រះនិព្វានមានអ្វីជាផល ?

វិ. អនិមិត្តប្បច្ចុប្បដ្ឋានំ= ព្រះនិព្វានមានការប្រាសចាកសង្ខតនិមិត្តជាផល ។ ម្យ៉ាងទៀតថា និប្បបញ្ចប្បច្ចុប្បដ្ឋានំ= ព្រះនិព្វានមានសភាវៈជាហេតុឲ្យរម្ងាប់នូវបបញ្ចធម៌ មានតាមភាគៈជាដើមជាផល ។

ប្ុ. និព្វាន មានប៉ុន្មាន?

វិ. និព្វាន មាន២យ៉ាងគឺៈ

សឧបាទិសេសនិព្វាន១ , អនុបាទិសេសនិព្វាន១ ។

បុ. សឧបាទិសេសនិព្វាននោះដូចម្តេច?

វិ. សឧបាទិសេសនិព្វាននោះ បានដល់ការរីងស្ងួតកិលេស តួយ៉ាងដូចកាលព្រះភគវន្តមុនី ស្តេចទ្រង់ប្រថាប់នៅលើរតនបល្លង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ ទ្រង់ផ្ចាញ់នូវមារាធិរាជព្រមទាំងពលឲ្យបរាជ័យ បាក់បបខ្លបខ្លាបព្រះអង្គ ហើយរំពឹងដល់ពុទ្ធប្បវេណី ដោយឈានសមាបត្តិ លះបង់នូវរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ព្រមទាំងកិលេស ១៥០០ តណ្ហា ១០៨ ឲ្យឃ្លាតចាកខន្ធសន្តានរបស់ព្រះអង្គ ដូចដំណក់ទឹកជ្រុះចុះចាកស្លឹកឈូក; យ៉ាងនេះហៅថា "សឧបាទិសេសនិព្វាន" ។

ពេលដែលព្រះអង្គបានសឧបាទិសេសនិព្វាននោះ ព្រះអង្គទ្រង់បន្លឺនូវឧទានវាចាថាៈ

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ

និព្វាន

សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ ។

អធិប្បាយតាមព្រះពុទ្ធដីកានោះថា:

កាលដែលតថាគត កំពុងស្វែងរកជាងឈើគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាពរបស់តថាគត, កាលដែលមិនទាន់ជួបប្រទះនៅឡើយ, តថាគតតែងតែអន្ទោលទៅកាន់សង្សារវដ្ត រាប់ជាតិជាអនេក (ម្ល៉ោះហើយ) ជាតិក៏តែងនាំសេចក្តីទុក្ខ មកឲ្យតថាគតរឿយ ៗ ឥតស្រាកស្រាន្តឡើយ ។ នែ! ជាងផ្ទះឥឡូវនេះតថាគត រកអ្នកឃើញហើយហ្នា! ពីថ្ងៃនេះទៅអ្នកឯងអស់ធ្វើផ្ទះ គឺអត្តភាពឲ្យតថាគតបានទៀតហើយ, បង្កង់គឺកិលេសដ៏សេសទាំងឡាយរបស់អ្នកឯង តថាគតកាប់បំបាក់អស់ទៅហើយ ទាំងកំពូលផ្ទះគឺអវិជ្ជាដែលអ្នកឯងធ្វើហើយនោះ, តថាគតក៏បានកំចាត់បង់ហើយ; ឥឡូវនេះ ចិត្តរបស់តថាគតបានព្រះនិព្វាន ដែលប្រាសចាកសង្ខារទាំងឡាយហើយ, តថាគតបានត្រាស់ដឹងនូវអរហត្ត ដែលជាធម៌

ក្ស័យនៃតណ្ហាទាំងឡាយហើយ ។

បុ· អនុបាទិសេសនិព្វាន នោះតើដូចម្ដេច?

វិ· អនុបាទិសេសនិព្វាននោះ គួរយ៉ាងដូចព្រះជិនស្រី ដែលទ្រង់បានដល់នូវព្រះសព្វញ្ញុតញ្ញាណហើយ, ទ្រង់គង់នៅប្រោសសត្វបានចំនួន៤៥ព្រះវស្សាហើយ, ស្ដេចយាងទៅផ្ទំលើទែនសិលាសនៈ ក្រោមលង្វែកមែកសាលព្រឹក្សទាំងគូ ក្បែរនគរកុសិនារា, ស្ដេចចូលកាន់ឈានសមាបត្តិ ហើយលះបង់នូវជីវិតាយុសង្ខារ ទ្រង់ធ្វើព្រះដំណើរចូលទៅកាន់ព្រះនិព្វានរំលត់ រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ឥតមានវិបាកក្ខន្ធ និងកម្មជរូបសេសសល់តិចតួចឡើយ; យ៉ាងនេះហៅថា "អនុបាទិសេសនិព្វាន" ។

បុ· និព្វាន មានត្រឹមតែ២យ៉ាងប៉ុណ្ណោះឬ?

វិ· មិនមែនមានត្រឹមតែ២យ៉ាងប៉ុណ្ណោះទេ, ៣ក៏មានគឺៈ សុញ្ញតនិព្វាន១, អនិមិត្តនិព្វាន១, អប្បណិហិតនិព្វាន១ ។

បុ· អធិប្បាយ នូវនិព្វានទាំង៣មកមើលៈ

និព្វាន

វិ. សុញ្ញតនិព្វាននោះ ជាអារម្មណ៍នៃអរិយមគ្គ ដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនា មានអនត្តាជាអារម្មណ៍, អនិមិត្តនិព្វាននោះ ជាអារម្មណ៍នៃអរិយមគ្គ ដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនា មានអនិច្ចាជាអារម្មណ៍, អប្បណិហិតនិព្វាននោះ ជាអារម្មណ៍នៃអរិយមគ្គ ដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនា មានទុក្ខាជាអារម្មណ៍ ។

បុ. និព្វាននោះ គេត្រូវដឹងដោយធម៌អ្វី?

វិ. និព្វាននោះ គេត្រូវដឹងដោយអរិយមគ្គញាណ ៤ ។

បុ. អរិយមគ្គញាណ ៤ នោះដូចម្តេច? ចូរអធិប្បាយ?

វិ. អរិយមគ្គញាណ ៤ នោះ ដូច្នេះគឺ:

មគ្គញាណ ជាបឋមនោះ ព្រះយោគាវចរគប្បីប្រាថ្នាឲ្យសំរេច មិនគប្បីធ្វើនូវកិច្ចដទៃទៀតឡើយ ត្រូវតែធ្វើនូវវិបស្សនាទីបំផុតនៃអនុលោមតែម្យ៉ាងឲ្យសម្រេច, កិលេសដែលបិទបាំងនូវសច្ចធម៌ ព្រះយោគាវចរកំចាត់បង់ដោយអនុលោម ៣

ចិត្តដែលមិនជាប់នៅក្នុងសង្ខារ មិនស្ទុះស្ទាទៅកាន់អារម្មណ៍, ដូចជាទឹកដែលមិនដក់នៅលើស្លឹកឈូកមាននិមិត្តជាអារម្មណ៍ នឹងមានការប្រព្រឹត្តទៅជាអារម្មណ៍ ទាំងនេះក៏កើតប្រាកដឡើង ដល់ព្រះយោគីដែលមានសេចក្តីខ្វល់ខ្វាយ, លំដាប់នោះព្រះយោគី ក៏បំពេញនូវអនុលោមញាណ ធ្វើនូវព្រះនិព្វានដែលមិនមាននិមិត្ត ប្រាសចាកសង្ខារឲ្យជាអារម្មណ៍ ហើយក៏កន្លងនូវបុថុជ្ជនគោត្រនឹងបុថុជ្ជនភូមិ ហើយឡើងកាន់អរិយគោត្រនឹងអរិយភូមិ គោត្រភូញាណ ក៏កើតឡើងប្រាកដ គោត្រភូ-ញាណ គ្របសង្កត់នូវការកើតឡើងនឹងការប្រព្រឹត្តទៅ ហើយស្ទុះទៅកាន់ព្រះនិព្វានជាអារម្មណ៍; ដូច្នេះ ឈ្មោះថា "គោត្រភូ" ។ ការប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ ដោយជវនតែមួយ, ឧបមាដូចបុរសលោតកន្លងនូវប្រឡាយទឹក មានប្រាជ្ញានឹងឆ្លងទៅត្រើយម្ខាង លុះទៅដល់ហើយ ក៏នៅស្ងៀម យ៉ាងណាមិញ, បំណែកព្រះយោគាវចរ ដែលមានប្រាជ្ញានឹងស្ថិតនៅត្រើយម្ខាងគឺព្រះនិព្វាន ដែលមិនមានកំណើតនឹងឋិតិនឹងទីលំ

នៅ ស្ទុះទៅដោយរហ័ស មានឧទយព្វយានុបស្សនាជាដើម បង់នូវមែកគឺអត្តភាព, ក្បួនគឺរូប, អនុលោមជវនដែលពិចារណា ឃើញអនិច្ចំ ទុក្ខំ អនត្តា ដូច្នេះ ក៏មិនព្រមលែងនូវរូបនោះ ហើយ លោតឡើងដោយអនុលោមចិត្តជាបឋម មានចិត្តទោរទន់ទៅ កាន់ព្រះនិព្វាន, ដូចជាកាយដែលទោរទន់ទៅកាន់ត្រើយម្ខាង ជិតព្រះនិព្វានដោយតតិយជវន៍ ដូចជាដល់ត្រើយខាងនាយ លែងពិចារណានូវសង្ខារ ដល់នូវត្រើយគឺព្រះនិព្វានដោយ គោត្រភូចិត្ត កិរិយាមិនញាប់ញ័រ ដោយមិនបានសេពគប់នូវ អារម្មណ៍តែមួយ, ដូចជាបុរសដែលមិនបានឈរស្រួល ក៏យ៉ាង នោះដែរ ។ អនុលោមញាណ កំចាត់បង់នូវងងឹត គឺកិលេស ដែលបិទបាំងនូវសច្ចៈ ៤ តែមិនអាចធ្វើនូវព្រះនិព្វានឲ្យជា អារម្មណ៍បាន មិនអាចកំចាត់បង់នូវងងឹតបានឡើយ, ឧបមាដូច បុរសម្នាក់មានភ្នែកភ្លឺ ដើរចេញទៅក្នុងវេលាយប់គិតថា អញ នឹងមើលនូវនក្ខត្តឫក្ស ហើយក្រឡេកមើលទៅខាងលើឃើញ ព្រះចន្ទ្រ តែមិនប្រាកដឡើយ ព្រោះមានពពកបាំង, លំដាប់

នោះ មានខ្យល់ខ្លះបក់ផាត់ពពកដ៏ក្រាស់, ខ្យល់ខ្លះបក់ផាត់ពពកយ៉ាងកណ្ដាល, ខ្យល់ខ្លះទៀតបក់ផាត់ពពកយ៉ាងល្អិត, បុរសនោះ ក៏ឃើញនូវព្រះចន្ទច្បាស់ ៗ ងងឹតគឺកិលេសដ៏ក្រាស់នឹងកិលេសដ៏ល្អិត ដូចជាពពកបីជាន់ដែលបិទបាំងនូវព្រះចន្ទ; អនុលោមចិត្ត ដូចខ្យល់កំចាត់បង់នូវពពក, គោត្រភូ ដូចបុរសមានភ្នែកភ្លឺ, ព្រះនិព្វាន ដូចព្រះចន្ទ, កំចាត់បង់នូវងងឹត ដែលបិទបាំងនូវសច្ចៈ ដោយអនុលោមចិត្តមួយ ៗ ដូចជាកំចាត់បង់នូវពពក ដោយលំដាប់នៃខ្យល់, ឃើញនូវព្រះនិព្វានដ៏ស្អាតដោយគោត្រភូញាណ កំចាត់បង់នូវងងឹតដូចជាបុរសឃើញនូវព្រះចន្ទដ៏ស្អាត ខ្យល់កំចាត់បង់នូវពពក តែមិនអាចឃើញខ្លួនឯងបាន យ៉ាងណា, បំណែកអនុលោមញាណកំចាត់បង់នូវកិលេស តែមិនអាចឃើញនូវព្រះនិព្វានដោយខ្លួនឯងបាន, គោត្រភូញាណ ឃើញនូវព្រះនិព្វាន តែមិនអាចកំចាត់បង់នូវកិលេសបាន ក៏យ៉ាងនោះដែរ ៗ មគ្គមិនលែងនូវសញ្ញា ដែលគោត្រភូញាណឲ្យសញ្ញា

និព្វាន

នោះត្រាស់ដឹង ដោយតៗគ្នាមិនដាច់ ហើយក៏ទម្លាយនូវគំនរ លោភៈ ទោសៈ មោហៈ, ឧបមាដូចបុរសអ្នកបាញ់ធ្នូ ហើយ ដម្រែតក្តារមួយរយជាន់ ក្នុងប្រមាណប៉ុនគោឧសភ ហើយយក សំពត់រុំមុខ កាន់ព្រួញឈរនៅទីបំផុត ហើយគេឲ្យបុរសដទៃ ទៀតទៅបង្វិលក្តារយន្តនោះ ឲ្យមានមុខទៅត្រង់ក្តារ ដែល បុរសនោះឈរនៅ ហើយទើបឲ្យសញ្ញាដោយបុងដម្បង, បុរសដែលបាញ់នោះ ក៏មិនលែងនូវសញ្ញាដោយបុងដម្បងនោះ ឡើយ ហើយបាញ់ព្រួញទៅ ក៏មុតក្តារមួយរយជាន់នោះ;គោត្រ ភូញាណ ដូចសេចក្តីសំគាល់ដោយបុងដម្បង, មគ្គញាណ ដែលទម្លាយបង់នូវលោភៈទោសៈ មោហៈ ដូចជាបុរសមិន លែងនូវសញ្ញាដោយបុងដម្បង ហើយបាញ់ទៅមុតក្តារមួយរយ ជាន់, មគ្គដែលដឹងដូច្នេះ ហៅថា "សោតាបត្តិមគ្គញាណ" ។

ព្រះអរិយបុគ្គលជាគំរប់ពីរ ឈ្មោះថា "សោតាបន្នបុគ្គល" ដែលអន្ទោលទៅមកក្នុងទេវតានឹងមនុស្សអស់ ៧ ដង ទើបធ្វើ នូវទីបំផុតនៃទុក្ខបាន, ចិត្តរបស់លោកយាងចុះកាន់ភវង្គៈ ជាទី

បំផុតនៃផល, លំដាប់នោះ មនោទ្វារាវជ្ជនៈ ផ្ដាច់បង់នូវភវង្គៈ ដែលកើតឡើងពិចារណានូវមគ្គ មនោទ្វារាវជ្ជនៈនោះរលត់ទៅ, ជវន ពិចារណានូវមគ្គទាំង ៧ ដោយលំដាប់ចិត្តដែលយាងចុះកាន់ភវង្គៈម្ដងទៀត ហើយពិចារណានូវផល ។

បច្ចវេក្ខណកិច្ច កិច្ចដែលសោតាបន្នបុគ្គលត្រូវពិចារណាមាន៥គឺៈ

១- មគ្គំ បច្ចវេក្ខតិ= ពិចារណានូវមគ្គដោយន័យថ្លែងថា "អាត្មាអញមកតាមផ្លូវណា";

២- ផលំ បច្ចវេក្ខតិ= ពិចារណានូវផលជាអានិសង្ស ដែលអញត្រូវបាន ;

៣- បហីនក្កិលេសំ បច្ចវេក្ខតិ= ពិចារណានូវកិលេសដែលខ្លួនលះបង់ហើយថា "កិលេសទាំងនេះ អញលះបង់បានហើយ";

-៤ អវសេដ្ឋកិលេសំ បច្ចវេក្ខតិ= ពិចារណានូវកិ-លេសដែលសល់នៅថាៈ "កិលេសទាំងអស់ដែលសល់នៅ

នេះ ត្រូវលះដោយមគ្គខាងលើ" ;

៥- និព្វានំ បច្ចវេក្ខតិ= ពិចារណានូវព្រះនិព្វានថា: "ធម៌នេះហើយដែលជាអារម្មណ៍ត្រូវត្រាស់ដឹង" ។

សោតាបន្នបុគ្គលមាន ៥ សកទាគាមិបុគ្គលមាន ៥ អនាគាមិបុគ្គលមាន ៥ ដូចគ្នា, ឯព្រះអរហន្ត មានតែ ៤ ; កិលេសដែលសល់នៅនោះ, ព្រះអរហន្តលោកគ្មានទេ ; អរិយៈជាសោតាបន្នបុគ្គលនោះ លោកគង់នៅលើអាសនៈមួយ ហើយលះបង់នូវកាមរាគៈ ព្យាបាទ: ដ៏ស្ដើង លោកប្រជុំ នូវឥន្ទ្រិយពលៈ ពោជ្ឈង្គៈ លោកញុំាញីនូវរូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ថាជា ទុក្ខំ, អនិច្ចំ, អនត្តា ចិត្តលោកក៏យាងចុះកាន់ថ្នល់គឺវិបស្សនា ; អនុលោមញ្ញាណ និងគោត្រភូញាណ ក៏កើតឡើងដោយជវនចិត្តតែមួយ ក្នុងទីបំផុតនៃសង្ខារុបេក្ខា, សកទាគាមិមគ្គ ក៏កើតឡើងក្នុងលំដាប់នៃគោត្រភូញាណ ដែលដឹងនូវសកទាគាមិមគ្គ ដូច្នេះ ហៅថា "សកទាគាមិមគ្គញ្ញាណ" ជាគំរប់ពីរ ។

អរិយបុគ្គលជាគំរប់ ៤ ឈ្មោះថា " សកទាគាមិបុគ្គល " លោកមកកាន់លោកនេះអស់វារៈម្តងទៀត ហើយពិចារណានូវបច្ចវេក្ខណៈ ៥ រួចលះបង់នូវកាមរាគៈ ព្យាបាទៈដែលនៅសេសសល់ លោកប្រជុំនូវឥន្ទ្រិយ ហើយញ៉ាំញីនូវបញ្ចក្ខន្ធលុះប្រព្រឹត្តដូច្នោះហើយ អនុលោមញ្ញាណនឹងគោត្រភូញ្ញាណក៏កើតឡើង ទាំងអនាគាមិមគ្គ ក៏កើតឡើងដែរ; ដូច្នេះហៅថា " អនាគាមិមគ្គញ្ញាណ " ជាគំរប់បី ។

អរិយបុគ្គលជាគំរប់ ៦ ឈ្មោះថា "អនាគាមិបុគ្គល" លោកបរិនិព្វានទៅក្នុងជាន់សុទ្ធាវាស លែងត្រឡប់មកកាន់កាមលោកនេះទៀតហើយ លោកពិចារណានូវមគ្គទាំង៤ ទំលះនូវរូបរាគៈអរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា ដែលសេសសល់នៅ លោកប្រជុំនូវឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ហើយញ៉ាំញីនូវបញ្ចក្ខន្ធថាជា ទុក្ខំ, អនិច្ចំ, អនត្តា អនុលោមញ្ញាណនឹងគោត្រភូញ្ញាណ ក៏កើតឡើង, អរហត្តមគ្គ ក៏កើតឡើងដែរ ។ ក្នុងលំដាប់នៃគោត្រភូញ្ញាណ ដែលដឹងនូវអរហត្តមគ្គ;

ដូច្នេះ ហៅថា " អរហត្តមគ្គញាណ " ជាគំរប់បួន ។

អរិយបុគ្គលជាគំរប់ ៨ ឈ្មោះថា " អរហន្តបុគ្គល " លោកជាព្រះខីណាស្រព លះបង់នូវសំយោជនៈទាំងអស់ គ្មានសល់ឡើយ ; ញាណទាំង៤នេះ ញាណដឹងបំពោះមគ្គបុគ្គលតាំងនៅក្នុងផល បានជាផ្លាស់គ្នា ជាលំដាប់ ៗ ញាណដែលដឹងនូវមគ្គទាំង ៤ , ដូច្នេះ ហៅថា " ញាណទស្សនវិសុទ្ធិ " ។

ធម៌ ដែលញាណទាំង ៤ ត្រាស់ដឹងបាននោះ គឺពោធិបក្ខិយធម៌ ៣៧ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិប្បាទ ៤ ឥន្ទ្រិយ ៥ ពលៈ៥ ពោជ្ឈង្គៈ ៧ អដ្ឋង្គិកមគ្គ ៨ ។

អរិយមគ្គញាណទាំង ៤ នេះ សម្រាប់ផ្ទះបញ្ជាំងមើលនូវព្រះនិព្វាន , បើបុគ្គលណាបង់ឃើញព្រះនិព្វាន លុះតែបំរើននូវអរិយមគ្គញាណទាំង៤នេះឲ្យកើតឡើង ទើបឃើញព្រះនិព្វានបាន , ឧបមាដូចមនុស្សបង់មើលនូវមុខខ្លួនឯង លុះតែយកកញ្ចក់ផ្ទះមើលទើបឃើញនូវមុខ យ៉ាងណា , ព្រះ

និព្វាន ក៏យ៉ាងនោះដែរ ។

ប. ដំណើរដែលសត្វទៅកាន់ព្រះនិព្វាននោះ តើត្រូវទៅតាមផ្លូវណា? មានអ្វីជាយានជំនិះ? ។

វ. សត្វដែលទៅកាន់ព្រះនិព្វាននោះ ត្រូវទៅដោយយានជំនិះ និងផ្លូវដែលព្រះអង្គសំដែងទុកមក ក្នុងធម្មចក្កប្បវត្តនសូត្រ ដោយព្រះគាថា ថាៈ

នេមិយំ ចតុសច្ចញ្ច អារាំ បច្ចយំ
មតំ នាភិចេវ សទ្ធម្មំ អញ្ញមញ្ញំ
បវត្តេត្តោ ធម្មចក្កិ បវត្តិ ។

អធិប្បាយតាមគាថានេះថាៈ

នេមិយំ ចតុសច្ចំ ព្រះធម្មចក្កប្បវត្តនសូត្រនេះ សម្តេចព្រះមុនីនាថ ទ្រង់ចាត់យកចតុរារិយសច្ចជាកង់ អារាំ បច្ចយំ ចាត់បច្ច័យគឺបដិច្ចសមុប្បាទនោះជាកាំ នាភិចេវ សទ្ធម្មំ ចាត់សត្តត្តឹសពោធិបក្ខិយធម៌នោះជាដុំ អញ្ញមញ្ញំ បវត្តេត្តោ សម្តេចព្រះជិនស្រីត្រាស់សំដែងនូវព្រះធម៌ទាំងពួងនេះ ឲ្យមាន

ន័យប្រព្រឹត្តទៅដល់គ្នានឹងគ្នា គឺព្រះអង្គទេសនា នូវបតុរារិយ-សច្ចនោះ មានន័យដល់បដិច្ចសមុប្បាទ រហូតដល់សត្តតិំស-ពោធិបក្ខិយធម៌នោះ, ដល់ទេសនាពោធិបក្ខិយធម៌វិញ ក៏ទេសនាឲ្យមានន័យដូចបដិច្ចសមុប្បាទ រហូតដល់បតុរារិយ-សច្ចផងដែរ, វេលាត្រាស់ទេសនាបដិច្ចសមុប្បាទនោះសោត ក៏ទេសនាឲ្យមានន័យដល់បតុរារិយសច្ច រហូតដល់ពោធិបក្ខិ-យធម៌ ដូចគ្នាដែរ ។

អាស្រ័យហេតុដែលព្រះអង្គត្រាស់ទេសនា ឲ្យមានន័យប្រព្រឹត្តទៅដល់គ្នានឹងគ្នាដូច្នេះ ទើបមានបញ្ញត្តថា "ធម្មចក្ក" មានឧបមាយ៉ាងណា, សកដចក្ករថចក្ក ក្ដី មានគណនាដូចជាចក្រដែលទៅដោយបក្ររថ ធម្មតាចក្រ ដែលទៅដោយបក្ររថ, កាលបើមានតែដុំ រកកង់រកកាំគ្មាន ឬមានតែកាំរកកង់រកដុំគ្មាន ក៏មិនទាន់បានឈ្មោះថាចក្ករថឡើយ, លុះតែព្រមទាំងដុំទាំងកង់ បរិបូណ៌គ្រប់របស់ទាំង ៣ នេះហើយទើបឈ្មោះថា "ចក្ករថ", បើនៅផ្សេង ៗ គ្នា មិនទាន់បញ្ចូល

ជាមួយគ្នា ក៏មិនទាន់ឈ្មោះថា បក្រវិលទៅដោយបក្ករបិនោះ ឡើយ, លុះតែនាយជាងដ៏ឆ្លាត យកដុំមកភ្ជាប់ជាមួយគ្នា ហើយយកកាំមកបោះក្នុងដុំ រួបយកកង់មកបំពាក់ពីលើកាំ ធ្វើឲ្យជាប់ជាមួយគ្នាស្រេចកាលណា, ក៏បាននាមប្រាកដថា បក្រវិលទៅដោយបក្ករបិ ក្នុងកាលណោះ សេយ្យថា មានឧបមាយ៉ាងណា, បតុរារិយសច្ចទាំង៤ គឺៈ ទុក្ខសច្ច, សមុទយសច្ច, និរោធសច្ច, មគ្គសច្ច នោះ កាលព្រះអង្គត្រាស់ទេសនា ត្រង់ទៅតាមរឿង បតុរារិយសច្ច តែមួយៗ បានសេចក្ដីនៅក្នុងបតុរារិយសច្ចនោះប្រាកដថា អរិយសច្ចទេសនា នឹងបានឈ្មោះថា ធម្មចក្កទេសនា ក៏ទេ, សត្តត្តឹសពោធិបក្ខិយធម៌ ក៏ដូចគ្នា, កាលបើព្រះអង្គសំដែងទៅតាម សត្តត្តឹសពោធិបក្ខិយធម៌ តែមួយៗ បានសេចក្ដីតែក្នុងពោធិបក្ខិយធម៌នោះឈ្មោះថា សត្តត្តឹសពោធិបក្ខិយធម្មទេសនា នឹងបានឈ្មោះថា ធម្មចក្កទេសនា ក៏ទេ, បដិច្ចសមុប្បាទ ក៏ដូចគ្នា, បើព្រះអង្គសំដែងបដិច្ចសមុប្បាទ ឈ្មោះថា បដិច្ចសមុប្បាទទេសនា នឹងឈ្មោះថា

ធម្មចក្កទេសនា ក៏ហៅមិនបាន, លុះត្រាតែព្រះអង្គសំដែងធម៌ទាំង៣គឺៈ ពោធិបក្ខិយធម្មទេសនា បដិច្ចសមុប្បាទទេសនា ចតុរារិយសច្ចទេសនា ឲ្យមានអត្ថទាក់ទងដល់គ្នានឹងគ្នា ទើបបានឈ្មោះថា ធម្មចក្កទេសនា ក្នុងកាលនោះ, មានឧបមេយ្យដូចជា កង់ , កាំ, ដុំ ដែលនាយជាងបញ្ចូលទៅជាមួយគ្នា ទើបឈ្មោះថា "ចក្រ" ដែលវិលដោយចក្ករបស់នោះ, ចតុរារិយសច្ចដែលចាត់ទៅជាកង់នៃធម្មចក្រនេះ បើសំដែងតែអរិយសច្ចឯណានិមួយ មិនសំដែងឲ្យព្រមទាំង ៤ មិនអាចឲ្យសម្រេចកិច្ចជាកង់នៃធម្មចក្របានឡើយ យ៉ាងណា, ដូចជានាយជាងបើធ្វើកង់មួយកំណាត់ ឬពីរកំណាត់ទេ ឲ្យឈ្មោះថាកង់រទេះមិនបានឡើយ, លុះតែព្រមដោយខ្នងកង់ ៤ កំណាត់ ទើបបានឈ្មោះថា ជាកង់រទេះ សេយ្យថា មានឧបមាយ៉ាងណាមិញ, អរិយសច្ច បើលុះណាតែគ្រប់ទាំង ៤ ទើបឈ្មោះថា អរិយសច្ចយ៉ាងនោះដែរ ។ ដែលចាត់យកបដិច្ចសមុប្បាទធម៌ ជាកាំនៃធម្មចក្រនោះគឺៈ អវិជ្ជា ជាកាំ ១, សង្ខារ ជាកាំ ១, វិញ្ញាណ

ជាកាំ១, នាមរូប ជាកាំ១, សឡាយតនៈ ជាកាំ១, ផស្សៈ ជាកាំ១, តណ្ហា ជាកាំ១, ឧបាទាន ជាកាំ១, ភព ជាកាំ១, ជាតិ ជាកាំ១, ជរាមរណៈ ជាកាំ១, ផ្សំគ្នាត្រូវជាកាំ ១២ប្រការ; ពោធិបក្ខិយធម៌៣៧ ប្រការនោះគឺៈ សតិប្បដ្ឋាន៤ សម្មប្បធាន ៤ ឥទ្ធិប្បាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គៈ៧ អដ្ឋង្គិកមគ្គ ៨, រួមជា៣៧; ចាត់ជាដុំនៃធម្មចក្រ ព្រោះជាទីប្រជុំនៃ បដិច្ចសមុប្បាទធម៌ មានអវិជ្ជា ជាដើម មានជរាមរណៈ ជា បរិយោសាន មានគណនាដូចដុំដែលវិលទៅដោយដុំនៃរថជា ទីប្រជុំនៃកាំទាំងពួង ធម្មតាកាំដែលវិលទៅនោះ រមែងប្រជុំ បុះទៅក្នុងដុំទាំងអស់ នឹងប្រាសចាកដុំក៏ទេ, ដុំជាទីប្រជុំនៃកាំ យ៉ាងណា, ពោធិបក្ខិយធម៌ ៣៧ ក៏ជាទីប្រជុំនៃបដិច្ចសមុប្បាទ ធម៌ យ៉ាងនោះដែរ ។

ព្រះយោគាវចរ បំរើនសួរពោធិបក្ខិយធម៌ មានសតិប្បដ្ឋាន ជាដើម មានអដ្ឋង្គិកមគ្គ ជាបរិយោសាន នឹងបានប្រាសចាក ការពិចារណាបដិច្ចសមុប្បាទក៏ទេ ត្រូវពិចារណាចាប់ផ្ដើម

តាំងពីអវិជ្ជា សង្ខារ រៀងៗទៅ ។

ហេតុនេះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តថា ព្រះធម៌ទេសនាដែលព្រះបរមសាស្ដាត្រាស់ទេសនានោះ មានពោធិបក្ខិយធម៌ជាដុំ, បដិច្ចសមុប្បាទជាកាំ, ចតុរារិយសច្ច ជាកង់ឲ្យមានអក្ខទាក់ទងដល់គ្នានឹងគ្នា ហើយក៏ផ្ទុកនូវកែវទាំងនេះគឺៈ សីលរតនំ កែវគឺសីល១, បញ្ញារតនំ កែវគឺបញ្ញា១, វិមុត្តិរតនំ កែវគឺវិមុត្តិ១, វិមុត្តិញាណទស្សនរតនំ កែវគឺបច្ចវេក្ខណញ្ញាណ១, ពោជ្ឈង្គរតនំ កែវគឺពោជ្ឈង្គៈ១, បដិសម្ភិទារតនំ កែវគឺបដិសម្ភិទា១, យោជិតំ ហើយព្រះអង្គប្រកបដោយធម្មរាជរថដ៏វិចិត្រដោយកែវទាំង៦ប្រការ, ព្រះទសពលញ្ញាណទ្រង់បាត់បែងនូវចក្រទាំង៤ ដោយចតុសច្ចញ្ញាណ គឺបញ្ញាដែលពិចារណាឃើញនូវអត្ថនៃអរិយសច្ចទាំង៤ សម្មប្បធានសន្ធឹទ្រង់ទឹមដោយសេះសន្ធវៈ គឺសម្មប្បធានទាំង៤ ជើនេយ្យបរិតំ ប្រាថ្នានឹងបរទៅកាន់ទិសដ៏ក្សេម គឺអមតមហានិព្វាន ពហលៈបង្កមគ្គំ ប្រាថ្នានឹងរាំងនូវផ្លូវប្រកបដោយភក់ គឺកាមសុខល្លិកា

នុយោគៈ ទុហានមគ្គ ប្រាជ្ញានឹងវាងនូវផ្លូវប្រកបដោយខ្សាច់ដ៏ក្តៅ គឺអត្តកិលមថានុយោគៈ ឧជុមគ្គ ប្រាជ្ញានឹងទៅតាមផ្លូវដ៏ត្រង់ គឺអដ្ឋង្គិកមគ្គទាំង៨ប្រការ ឆ្លងវាលធំ៣ គឺភពទាំង៣ ទៅដល់ស្រុកដែលជាទីក្សេមសប្បាយគឺព្រះនិព្វាន ។

នឹងអធិប្បាយអំពីអដ្ឋង្គិកមគ្គជាបច្ច័យដល់គ្នានឹងគ្នាដូច្នេះ គឺសម្មាសង្កប្បៈ ជាបច្ច័យដល់សម្មាទិដ្ឋិ ប្រៀបដូចមនុស្សយកដៃចាប់មាសមកផ្ទៀងផ្ទង់មើល សម្មាសង្កប្បៈ ដូចជាដៃ សម្មាទិដ្ឋិ ជាភ្នែក សម្រាប់មើលឲ្យស្គាល់ថាល្អឬអាក្រក់ សម្មាវាចា សម្មាកម្មន្តោ ជាបច្ច័យដល់សម្មាអាជីវោ កាលបើប្រព្រឹត្តកាយវាចាសុចរិតហើយ ការចិញ្ចឹមជីវិតក៏ជាសុចរិតដែរ សម្មាវាយាមោ សម្មាសតិ ជាបច្ច័យដល់សម្មាសមាធិ ប្រៀបឧបមាដូចមនុស្ស៣នាក់ជាសំឡាញ់នឹងគ្នា ដើរទៅក្នុងសួនឧទ្យាន នាំគ្នាបេះផ្កាចម្ប៉ាមានដើមដ៏ខ្ពស់ សំឡាញ់ទី១ បង្អោនស្មាឲ្យសំឡាញ់ទី៣ជាន់ ហើយក៏ប្រឹងឈរឲ្យត្រង់ឫន សំឡាញ់ទី២អ្នកឈរអែប មិនឲ្យទ្រេតទ្រោតទៅបាន

ទើបឈោងបេះយកផ្កាបម៉្យាបាន មានឧបមាយ៉ាងណា, បំណែកសម្មាវាយាមៈ ដូចជាសំឡាញ់ទី១ សម្មាសមាធិ ដូចជាសំឡាញ់ទី ៣ ដែលឡើងជាន់លើស្មា សម្មាសតិ ដូចជាសំឡាញ់ទី ២ ដែលឈរអែបខ្សែនឹង ផ្កាបម៉្យាដូច អរិយមគ្គ មានឧបមេយ្យដូច្នោះដែរ ។

បើចាត់ដោយវិជ្ជានឹងបរណៈ វិញដូច្នេះគឺៈ សម្មាទិដ្ឋិ, សម្មាសង្កប្បៈ ជាវិជ្ជា; សម្មាវាចា, សម្មាកម្មន្តោ, សម្មាអាជីវោ, សម្មាវាយាមោ, សម្មាសតិ, សម្មាសមាធិ ទាំង៦នេះ ជាបរណៈ ។

វិជ្ជា ដូចបក្ខទាំងពីរ, បរណៈ ដូចជើងទាំងពីរ ។

អធិប្បាយថាៈ

បុគ្គលដែលដើរទៅតាមផ្លូវនោះ បើមានភ្នែកភ្លឺបរិសុទ្ធ ហើយរមែងមើលឃើញនូវផ្លូវដែលប្រកបដោយសេចក្តីអន្តរាយ, បើមានជើងទាំងពីរ ទើបដើរទៅតាមផ្លូវដោយស្រួលបាន យ៉ាងណា, បំណែកព្រះយោគាវចរ ដែលបំរើនអដ្ឋង្គិកមគ្គទាំង ៨

ប្រការ ឃើញនូវហេតុផលថា ប្រតិបត្តិយ៉ាងនេះ ជាហេតុឲ្យបានសេចក្តីសុខ យ៉ាងនោះដែរ ។

បដិបទា

បុ. បុគ្គលទៅកាន់ព្រះនិព្វាន មានផ្សេងគ្នាឬដូចគ្នា?

វិ. មានដំណើរផ្សេងគ្នា ៤ យ៉ាងគឺ :

១- ទុក្ខា បដិបទា ទន្ធាភិញ្ញា = កាលប្រតិបត្តិលំបាកដល់បានត្រាស់ដឹង ក៏លំបាក ។

២- សុខា បដិបទា ទន្ធាភិញ្ញា = កាលប្រតិបត្តិងាយដល់បានត្រាស់ដឹង បែរជាយឺតយូរវិញ ។

៣- ទុក្ខា បដិបទា ខិប្បាភិញ្ញា - កាលប្រតិបត្តិលំបាកត្រាស់ដឹងឆាប់ ។

៤- សុខា បដិបទា ខិប្បាភិញ្ញា = កាលប្រតិបត្តិងាយដល់ត្រាស់ដឹងក៏ឆាប់ ។

បុ. អ្វីឲ្យរហ័ស អ្វីឲ្យយឺតយូរ?

វិ. ព្រោះបុគ្គលប្រតិបត្តិនោះ មានឥន្ទ្រិយនឹងកិលេស

ផ្សេងគ្នាគឺៈ

១- បុគ្គលដែលប្រតិបត្តិយឺតយូរ ព្រោះកិលេសក្លៀវក្លា បានត្រាស់ដឹងយឺតយូរ ព្រោះឥន្ទ្រិយទន់, ប្រៀបឧបមាដូចជាអ្នកមានជម្ងឺជាទម្ងន់ដើរទៅផ្ទះគ្រូពេទ្យ, ដំណើរដែលទៅនោះជាដំណើរយឺតយូរ ព្រោះខ្លួនឈឺធ្ងន់ បានទៅដល់ផ្ទះគ្រូពេទ្យហើយ ក៏រកសុំថ្នាំៗនោះក៏បានតិច ម្ល៉ោះហើយជម្ងឺនោះ ក៏បានសះស្បើយដោយយឺតយូរ យ៉ាងណាមិញ, ទុក្ខាបដិបទា ទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

២- ប្រតិបត្តិងាយ ត្រាស់ដឹងយឺតយូរ ព្រោះកិលេសតិច ឥន្ទ្រិយទន់, ឧបមាដូចជាអ្នកមានជម្ងឺស្រាល ដើរទៅរកផ្ទះពេទ្យឆាប់ដល់ តែព្យាបាលរោគយូរ ព្រោះមានថ្នាំតិចយ៉ាងណាមិញ, សុខា បដិបទា ទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៣- ប្រតិបត្តិលំបាក ត្រាស់ដឹងឆាប់ ព្រោះកិលេសក្លៀវក្លា ឥន្ទ្រិយក៏ក្លៀវក្លា; ឧបមាដូចអ្នកមានជម្ងឺធ្ងន់ ដើរទៅ

រកផ្ទះពេទ្យឃើតយូរ តែបានសះជារោគឆាប់រហ័ស ព្រោះមានថ្នាំច្រើន យ៉ាងណាមិញ, ទុក្ខា បដិបទា ខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៤- ប្រតិបត្តិងាយ ត្រាស់ដឹងឆាប់ ព្រោះកិលេសទន់ឥន្ទ្រីយក្លៀវក្លា, ឧបមាដូចអ្នកមានជំងឺស្រាល ដើរទៅរកផ្ទះគ្រូពេទ្យឆាប់ដល់ រក្សារោគ ក៏ឆាប់សះជា ព្រោះមានថ្នាំច្រើន យ៉ាងណាមិញ, សុខា បដិបទា ខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

តួកិលេសទុកដូចជារោគ, ឥន្ទ្រីយ ៥ ទុកដូចជាថ្នាំសម្រាប់កែរោគ ។

មួយ៉ាងទៀត ឧបមាដូចបុរស៤នាក់ ស្វែងរកគោ, បុរសទី១ដើរទៅក្នុងព្រៃ ដល់វេលាឃើញគោ ក៏ឃើញក្នុងព្រៃ យ៉ាងណាមិញ , ទុក្ខា បដិបទា ខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី២ ដើរទៅរកគោ ដើរតាមផ្លូវស្រួល ដល់ឃើញគោបែរជាឃើញក្នុងព្រៃវិញ យ៉ាងណាមិញ, សុខា បដិបទា

ទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី៣ស្វែងរកគោ ដើរកាត់ព្រៃ ដល់ឃើញគោ បែរជាឃើញក្នុងទីវាលវិញ យ៉ាងណាមិញ, ទុក្ខា បដិបទា ខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី៤ដើរទៅរកគោតាមផ្លូវល្អ ដល់ឃើញគោ ក៏ឃើញក្នុងទីវាល យ៉ាងណាមិញ, សុខា បដិបទា ខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

បុរសគឺព្រះយោគាវចរកុលបុត្រ ដែលស្វែងរកអរិយមគ្គ, ព្រៃគឺកិលេស, ផ្លូវល្អគឺកិលេសដ៏ស្តើង, បុគ្គលដែលបានមគ្គផល ផ្សេងគ្នាដូច្នេះ ព្រោះប្រតិបត្តិខុសគ្នាដូចសំដែងមកនេះ ។

បុច្ឆា-វិស្សជ្ជនា មកក្នុងព្រះនិព្វាន ព្រមទាំងសេចក្តីប្រៀបធៀបដោយបក្ករថ នឹងផ្លូវទៅកាន់ព្រះនិព្វាន ដើម្បីជាប្រយោជន៍ដល់សិក្ខាកាមទាំងឡាយមានបញ្ញាតិច នឹងចូលចិត្តដោយងាយ ក៏ចប់ដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

### បាលីសំដែងបដិបទារបស់និព្វាន

១- អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សី វា

អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។

ភិក្ខុមានសេចក្តីត្រេកអរក្នុងអប្បមាទធម៌ មានកិរិយា ឃើញនូវភ័យក្នុងបមាទធម៌ជាប្រក្រតី ពុំគួរដល់ការ សាបសូន្យ ឈ្មោះថាប្រតិបត្តិជិតព្រះនិព្វាន ។

២- សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
សមាធិគរុ អាតាបី សិក្ខាយ តិព្វគារវោ
អប្បមាទគរុ ភិក្ខុ បដិសណ្ឋារគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។

ភិក្ខុគោរពចំពោះព្រះសាស្តា គោរពចំពោះធម៌នឹង គោរពដ៏ក្លៀវក្លាចំពោះព្រះសង្ឃ, គោរពក្នុងសមាធិ មានព្យាយាមដ៏រឹងប៉ឹង គោរពដ៏ក្លៀវក្លាក្នុងសិក្ខា គោរពក្នុងអម្បមាទធម៌ គោរពក្នុងបដិសណ្ឋារៈ ពុំគួរ ដល់ការសាបសូន្យ ជាអ្នកជិតនឹងព្រះនិព្វាន ។

៣- យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ

ឈាននឹងបញ្ញា មានក្នុងបុគ្គលណា, បុគ្គល

នោះ ឈ្មោះថា ជិតព្រះនិព្វាន ។

៤- តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

អ្នកប្រាជ្ញទាំងឡាយ ចូលឈាន មានព្យាយាមដ៏ខ្ជាប់ខ្ជួនជានិច្ច រមែងពាល់ត្រូវនូវព្រះនិព្វាន ដ៏ក្សេមចាកយោគៈ រកគុណជាតិដទៃក្រៃលែងជាងគ្មាន ។

៥- សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។

ភិក្ខុ អ្នកស្ដារនូវទូកនេះ ទូកដែលអ្នកស្ដារហើយ នឹងដល់នូវការរហ័ស, បុគ្គល ដែលកាត់នូវរាគៈ ទោសៈ នឹងដល់នូវព្រះនិព្វាន ក្នុងលំដាប់នោះ ។

អធិប្បាយថា

ទូកគឺអត្តភាព ដែលបុគ្គលស្ដារហើយនោះគឺ បន្ទោបង់នូវកិលេស ឬបាបធម៌ បានរហ័សដល់គឺព្រះនិព្វាន ។,

៦- សតិ កាយគតា ឧបដ្ឋិតា

បដិបទា របស់និព្វាន

ឆសុ ផស្សាយតនេសុ សំវុតោ
សតតំ ភិក្ខុ សមាហិតោ
ជញ្ញា និព្វានមត្តនោ

ភិក្ខុដម្កល់ខ្ជាប់នូវកាយគតាសតិ សង្រួមក្នុងការ
កើតនៃផស្ស:ទាំង៦ មានចិត្តតាំងមាំរឿយ ៗ ហើយ
គប្បីដល់នូវព្រះនិព្វាន ជារបស់នៃខ្លួន ។

បាលីសំដែងឧបាទិសេសនិព្វាន

១- តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ
ដែលហៅថា ព្រះនិព្វានព្រោះលះនូវតណ្ហា ។

២- សព្វសោ តណ្ហានំ ខយា អសេសវិរាគនិរោធោ និព្វានំ
ការរលត់នូវរាគៈ ដោយមិនសល់ ព្រោះការអស់ទៅ
នៃតណ្ហាទាំងឡាយដោយសព្វគ្រប់ ឈ្មោះថាព្រះ
និព្វាន ។

៣- ឯកាហិ ធាតុ ឥធ ទិដ្ឋធម្មិកា
សឧបាទិសេសា ភវនេត្តិសង្ខយា

ធាតុមួយប្រព្រឹត្តទៅក្នុងធម៌ដែលគេឃើញហើយក្នុងលោកនេះ ជានិព្វានធាតុ មានឧបាទិសល់នៅព្រោះអស់ធម្មជាត ដែលនាំទៅកាន់ភព (គឺតណ្ហា) ។

បាលីសំដែង អនុបាទិសេសនិព្វាន

១– អកិញ្ចនំ អនាទានំ ឯតំ ទីបំ អនាបរំ
និព្វានំ ឥតិ មំ ព្រូមិ ជរា មច្ចុ បរិក្ខយំ ។

តថាគត ពោលថា ទ្វីបនេះ មិនមែនដទៃ បាលីសំដែងអនុបាទិសេសនិព្វាន មិនមានកង្វល់ មិនមានសេចក្តីប្រកាន់ ជាទីអស់ទៅនៃជរានឹងមច្ចុ ឈ្មោះថាព្រះនិព្វាន ។

២– អនុបាទិសេសា បន សម្បរាយិកា
យម្ហិ និរុជ្ឈន្តិ ភវានិ សព្វសោ ។

បំណែកធាតុដែលប្រព្រឹត្តទៅក្នុងធម៌ ដែលបុគ្គលគប្បីដល់ព្រមក្នុងខាងមុខ ដែលភពទាំងពួងរលត់ដោយប្រការៈទាំងពួង ជានិព្វានធាតុ រកឧបាទិមិន

មានឡើយ ។

៣- តេសំ វូបសមោ សុខោ ការចូលទៅជិតរម្ងាប់នូវសង្ខារទាំងឡាយនោះនាំមកនូវសេចក្តីសុខ ។

៤- អត្ថិ ភិក្ខុ តទាយតនំ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមាននៅ, ទី,ដី, ទឹក, ភ្លើង, ខ្យល់, មិនមានឡើយ ។

អាកាសានញ្ចាយតនវិញ្ញាណញ្ចាយតនអាកិញ្ចញ្ញា-យតននេវសញ្ញានាសញ្ញាយតនៈក៏មិនមែន, លោកនេះក៏មិនមែន, លោកដទៃក៏មិនមែន, ដួងព្រះចន្ទ្រក៏មិនមែន, ដួងព្រះអាទិត្យក៏មិនមែន, មួយទៀតភិក្ខុទាំងឡាយ តថាគតមិនបានពោលឡើយថា អាយតនៈនេះជាការមក ជាការនៅ ជាការដេក ជាការចុតិ ជាការកើត អាយតនៈ នោះរកទីតាំងអា-ស្រ័យមិនបាន មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ នោះឯងហើយជាទីបំផុតនៃទុក្ខ ក្នុងសូត្រនេះ ហៅ